# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ឈ្មោះ សោ សេងលី ហៅ ង៉ុយ ភេទប្រុស-០៩៤៧៧ (បាត់ខ្លួន)
## មុខងារៈ មន្ទីរពិសោធន៍ទស្សនាហកម្ម
## ជួបសម្ភាសន៍ជាមួយអ៊ំស្រី សោ គីមឃន អាយុ៦៥ឆ្នាំ ជាប្អូនស្រី
## នៅភូមិរំចេក៤ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង
## នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៦

ដោយៈ ឆាយ ណារឿន

ណារឿនៈ ដូចខ្ញុំជំរាបប្រាប់អ៊ំដំបូងអញ្ចឹងថាពួកខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ខាងទស្សនាវដ្ដីស្វែងរកការពិតនេះ ។ពួកខ្ញុំសិក្សាស្រាវជ្រាវរឿងរ៉ាវដែលកើតឡើងនៅក្នុងសម័យ ខ្មែរក្រហមអ្នកស់ ។ ហើយខ្ញុំមកដដល់ជួបអ៊ំដោយសារខ្ញុំមានប្រវត្តិរូបដែលត្រូវជា បងប្រុសរបស់អ៊ំ ឈ្មោះ សេង លី ។

ឃនៈ ចា៎ ! ស សេងលី ។

ណារឿនៈ អញ្ចឹងដំបូងខ្ញុំសូមស្គាល់ឈ្មោះអ៊ំផង អ៊ំឈ្មោះអីដែរ?

ឃនៈ ខ្ញុំឈ្មោះ និយាយឈ្មោះដើមទៅ ស គីមឃន ។

ណារឿនៈ ស គីមឃន ។ អ៊ំសព្វថ្ងៃអាយុប៉ុន្មានហើយ?

ឃនៈ អាយុ ៦៥ ។

ណារឿនៈ អញ្ចឹងអ៊ំត្រូវជាប្អូនបង្កើតរបស់អ៊ំ សេងលី?

ឃនៈ ចា៎!

ណារឿនៈ អ៊ំភូមិនេះគេហៅភូមិអីដែរ?

ឃនៈ ភូមិនេះគេហៅរំចេក៤ ។ នេះយើងនៅថ្មីទេណា មិនមែនទីតាំងយើងពីដើមទេ ពីដើមយើងនៅផ្សារលើ ។

ណារឿនៈ ឃុំអីដែរ?

យនៈ ឃុំរតនៈ ។

ណារឿនៈ នៅស្រុកសង្កែ ឬស្រុកបាត់ដំបង?

យនៈ ស្រុកបាត់ដំបង ។ អត់ដែលឮសោះ ដល់ឮស្រណោះណាស់ លែងគិតទៅ ហើយមើលទៅ គេថាសាប់ហើយ មើលហោគ្រប់កន្លែង ម៉ែខូចទៀតទៅ ហើយហ្នឹងម្តាយខ្ញុំទើបតែ ខូចដែរហ្នឹងណា អ! ចាំកូនណាស់លោកអើយ ។

ណារឿនៈ អ៊ំ ស្រុកកំណើតកើតជារបស់អ៊ំ នៅភូមិឃុំហ្នឹងដដែលឬអត់ទេ?

យនៈ ទេ!ខ្ញុំកើតផ្សារលើ ។ ភូមិផ្សារលើ នៅផ្សារលើទាំងអស់គ្នាហ្នឹងបងប្រុសខ្ញុំក៏កើតនៅផ្សារលើ ត្រើយម្ខាងនេះ ។

ណារឿនៈ នៅឃុំអីដែរផ្សារលើហ្នឹង?

យនៈ នៅបាត់ដំបង ឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង អានេះយើងពីដើមអ្នកស៊ ។

ណារឿនៈ បាទ! ស្រុកសង្កែ ខេត្តបាត់ដំបង ។ អញ្ចឹងអ៊ំខ្ញុំសូមស្គាល់ឈ្មោះឪពុកអ៊ំផងគាត់ឈ្មោះអីដែរ?

យនៈ ស ឆេងស្នួន ។

ណារឿនៈ ស ឆេងស្នួន ។ សព្វថ្ងៃគាត់នៅរស់ ឬខូចហើយ?

យនៈ ខូចអស់ហើយ ។

ណារឿនៈ គាត់ខូចសម័យខ្មែរក្រហមឬ..?

យនៈ នែ៎! សម័យយើងឥឡូវនេះ ៨០ជាង ។

ណារឿនៈ ដោយសាអីដែរ?

យនៈ ទេជម្ងឺ បាត់តែបងមួយទេមួយជីវិតអាពតនេះ ។

ណារឿនៈ ចុះម្តាយលោកយាយឈ្មោអីដែរ?

យនៈ ម្តាយឈ្មោះ តាន់ យៀកបួយ ។

ណារឿនៈ សព្វថ្ងៃគាត់...

យនៈ ខូចអស់ហើយ ។

ណារឿនៈ គាត់ខូចក្រោយខ្មែរក្រហមទេ?

យនៈ ទើបតែខូចនេះឯង ៩៧ ។

ណារឿនៈ អ៊ំមានបងប្អូនទាំងអស់ប៉ុន្មាននាក់ដែរ?

យនៈ ទាំងអស់នៅតែពីនាក់ទៀតទេណា អាស៊ូ អាសៀងហ្នឹង អាដុកទ័រស្ដេចហ្នឹង ។

ណារឿនៈ បើគិតទាំងស្លាប់ទាំងរស់?

យនៈ ទាំងស្លាប់ទាំងរស់ ៦ ។

ណារឿនៈ មាន៦នាក់ ។

យនៈ ស្រីតែមួយខ្ញុំហ្នឹង ។

ណារឿនៈ ស្រីតែមួយទេ ។

យនៈ ចាំ! ស្រីមួយ ។

ណារឿនៈ ចុះអ៊ំ សេងលីហ្នឹងគាត់ត្រូវជាកូនទីប៉ុន្មានដែរបើគិតទៅ?

យនៈ កូនទីមួយ វា៦០ប្លាយហើយបើនៅ ៦៩ហើយ ។

ណារឿនៈ គាត់កើតឆ្នាំអី?

យនៈ ឆ្នាំរោង មើល៦៩ ឆ្នាំ១៩០០ប៉ុន្មាន?

ណារឿនៈ បើសិននៅរស់គាត់អាយុ ៦៩ ហើយ?

យនៈ ចាំ! ៦៩ហើយ បងខ្ញុំ៤ឆ្នាំ ។ ៦៧ទេ ។

ណារឿនៈ គាត់ឆ្នាំរោងខ្ទង់៦០ ៦៧ត្រូវហើយ ។ អញ្ចឹងខ្ញុំសូមសួរខ្លះៗទាក់ទងប្រវត្តិគាត់កាលអ៊ំ សេងលីគាត់នៅពីក្មេងៗអ្នកាស់ ។ កាលនៅក្មេងគាត់បានរៀនដែរទេ?

យនៈ គាត់ជាប់បាក់ឌុប ។ ជាប់បាក់ដុប៥៩ សីហនុយកទៅ ៦០ ។ លេខមួយមួយស្រុកខ្មែរណា មិនមែននិយាយលេងទេ រៀនពូកែណាស់លេខមួយមួយស្រុកខ្មែរអ្នកាស់ ។

ណារឿនៈ អ៊ំអាចរៀបរាប់កាលពីដំបូងមកគាត់រៀននៅសាលាណា កាលពីបឋមសិក្សាអ្នកាស់ ។

យន: នៅរៀនទក្ខិណៈសាលា ។ សាលាវត្តកំផែងហ្នឹងគេហៅទក្ខិណៈសាលា ។

ណារឿន: សាលាហ្នឹងជាសាលា...

យន: សាលារដ្ឋ ។

ណារឿន: មិនមែនសាលាលោកទេ?

យន: ទេ សាលារដ្ឋគឺនៅជាប់សាលាសម្តេចឪធ្វើថ្មីនោះ ។ ឥឡូវដាក់សាលាវត្តកំផែងវិញហើយ ទក្ខិណៈសាលាយើងពីដើម អាហ្នឹងឈ្មោះយើងពីដើមអ្ហាស៎ ហើយដូចមន្ទីរពេទ្យអញ្ចឹងអាហ្នឹងឈ្មោះពីដើម រៀនប្អូករហូតអត់មានដែលអស់លុយម៉ែឪទេ រៀនពូកែណាស់ ។

ណារឿន: ទក្ខិណៈសាលាជាបឋមសិក្សា ឬជាអនុវិទ្យាល័យ?

យន: អត់ទេបឋមសិក្សា ដល់នេះទៅរៀនប្រលងចូលលីសេនេះ ចូលលីសេមន្ទីរពេទ្យរហូត ។

ណារឿន: គាត់ប្រលងចូលលីសេនៅភ្នំពេញ?

យន: អត់ទេ នៅមន្ទីរពេទ្យនេះសិន រួចបានទៅប្រលង ។

ណារឿន: នៅទីរួមខេត្តបាត់ដំបង?

យន: ចា៎! បាត់ដំបង ។

ណារឿន: ប្រហែលជានៅឆ្នាំណាដែលគាត់បានប្រលងចូលលីសេនៅបាត់ដំបងហ្នឹង?

យន: មិនចាំ ចាំតែគាត់ជាប់បាក់ឌុប ។

ណារឿន: គាត់ជាប់បាក់ឌុបនៅឆ្នាំណាដែរ?

យន: ឆ្នាំ ១៩៥៩ ។

ណារឿន: បាក់ឌុប លីសេហ្នឹងបាក់ឌុបហើយអ្ហែស?

យន: ចា៎!

ណារឿន: ពេលគាត់ជាប់បាក់ឌុបឆ្នាំ ១៩៥៩ ហ្នឹងហើយគាត់ទៅណាទៀត?

យន: ឆ្នាំ ១៩៦០ សី ហនុ យកទៅ ។ លេខមួយជំរើសថ្នាក់ស្រុកខ្មែរ ។

ណារឿន: គាត់ជាប់លេខមួយ?

យន៖ ចាំ! លេខមួយស្រុកខ្មែរ ។ ល្បីផ្អើលអស់ហើយ ហើយអត់មានម៉ែ ម្ដាយគាត់មានប្ដីមួយទៀតទៅណា រសាត់អណ្ដែតពីរនាក់បងប្អូនគាត់ខឹងណាស់ប្រឹងរៀនដល់ហើយ ។ ល្អណាស់លោកអើយមិនចេះឲ្យពិបាកទេ នៅជាមួយជីដូន ។

ណារឿន៖ កាលដែលគាត់ជាប់បាក់ឌុបឆ្នាំ ១៩៦០ហ្នឹងសម្ដេច សី ហនុ យកគាត់ទៅ?

យន៖ ចប់៥៩ ៦០បានទៅ ។

ណារឿន៖ បាទ!

យន៖ យកទៅបួករហូត ។

ណារឿន៖ យកទៅរៀននៅណាដែរ?

យន៖ នៅស៊ីសស្រុកបារាំងហ្នឹង ស៊ីសអ្អែសស្រុកបារាំងហ្នឹង ស៊ីសអ្អែសបានប្រពន្ធស៊ីសស្រុកបារាំងហ្នឹងបានប្រពន្ធស៊ីស ។ មិនមែនទេហៅបារាំង ។

ណារឿន៖ កាលគាត់ជាប់លេខមួយហ្នឹងគាត់ជាប់លេខមួយទូរទាំងប្រទេសឬទូរទាំងខេត្ត?

យន៖ ទូរទាំងប្រទេស ។

ណារឿន៖ ទូរទាំងប្រទេស ។ អញ្ចឹងមូលហេតុដែលថាគាត់ប្រលងជាប់លេខមួយទូរទាំងប្រទេសហ្នឹងបានសម្ដេចសី ហនុ យកគាត់ទៅរៀននៅបារាំង?

យន៖ ចាំ! ចេញឲ្យទាំងអស់ ហើយទៅជាប់បួកនៅស្រុកបារាំងទៀត ។

ណារឿន៖ អ៊ំដឹងថាគាត់ទៅរៀនផ្នែកអីដែរអត់ពេលទៅរៀននៅស្រុកបារាំងហ្នឹង?

យន៖ អាំងស៊ីញើគេប៉េប៉ុងសាសុះសេ ។

ណារឿន៖ អាហ្នឹង...

យន៖ ខាងប្លង់ផ្ទះហើយហ្នឹងស្ពាន ។

ណារឿន៖ អ៊ំចេះបារាំងច្រើន?

យន៖ អត់ទេ ភ្លេចអស់ហើយ ខ្ញុំឈប់យូរហើយគ្រាន់តែចេះបន្តិចបន្តួចហ្នឹង ។ វិស្វករអ្អែស?

ណារឿនៈ ខាងវិស្វករសំណង់ ។

យនៈ ពួកម៉ាកថាអនេះរៀនពូកែមែនមកពីស្រុកបារាំងអ្ហាស៎ ថាកុំឲ្យតែវ៉ាបែកឆ្វេង វ៉ាន់ដេត តើថាកុំឲ្យតែអាសេងលីបែកឆ្វេង តែចូលក្រហមពិបាកណាស់អ៊ំ គាត់សរសេរសំបុត្រមកប្រាប់ខ្ញុំអ្ហាស៎ ។ ខ្ញុំចេះតែថាបងកុំឲ្យធ្វើផ្តេសផ្តះអញ្ចឹងអ្ហាស៎ កុំឲ្យចូលបក្សក្រហមអីអ្ហាស៎ដល់ពេលអញ្ចឹងទៅ បាត់ដំណឹងឈឹងលែងឲ្យយើងដឹង អត់មានឲ្យដំណឹង ទៀតបាត់រហូត ។

ណារឿនៈ អ៊ំម៉េចដឹងថាសម្តេច សី ហនុ បញ្ជូនគាត់ទៅស្រុកបារាំងកាលហ្នុង?

យនៈ ចុះបើម៉ែខ្ញុំអីឡើងទៅគេ...

ណារឿនៈ មានទៅជូនដំណើរដែរទេ?

យនៈ ជូន ជូនដំណើរណាឡើងយន្តហោះនោះ ។ គឺថាគេរាប់រងទាំងអស់ អត់ពិបាកទេ ។ ទៅដល់ស្រុកបារាំងក៏មិនដែលផ្ញើលុយមួយរៀលដែរ យើងក្រយើងអត់មានលុយទេ យើងអ្នកក្រយើងអត់មានលុយទេ ។

ណារឿនៈ អញ្ចឹងអ៊ំទៅជូនដំណើរគាត់ដល់ប្រលានយន្តហោះដែរអ្ហែស?

យនៈ ចា៎! ទៅទាំងអស់គ្នាម៉ែខ្ញុំអីទៅទាំងអស់គ្នា ។

ណារឿនៈ កាលអ៊ំទៅជូនដំណើរហ្នឹងមាននិស្សិតខ្មែរយើងទៅច្រើនដែរទេ ឬទៅតែគាត់ម្នាក់ឯងទេ ទៅកាលហ្នឹង ពេលឡើងយន្តហោះអ្ហាស៎?

យនៈ ឡើងយន្តហោះមានប៉ុន្មាននាក់ទេ ពេលចេញទៅជាមួយហ្នឹង ។

ណារឿនៈ មានអ្នកនៅក្នុងខេត្តបាត់ដំបងហ្នឹងទៅដែរទេ?

យនៈ មាន ។

ណារឿនៈ អ៊ំស្គាល់ដែរទេពីណាគេ?

យនៈ មិនស្គាល់ តែអ្នកទៅជាមួយហ្នឹងសុទ្ធតែពួករៀនជាមួយគ្នាខ្ញុំអត់ស្គាល់ទេ ខ្ញុំនៅក្មេងដែរហ្នឹងមានទៅស្គាល់អី ខ្ញុំនៅអាយុប៉ុន្មានដប់ហ្នឹង ។

ណារឿនៈ

ពេលគាត់ទៅឡើងយន្តហោះហ្នឹងពេលទៅជូនដំណើរហ្នឹងមានអ្នកធ្វើការធំៗសម័យហ្នឹង ដូចជាមន្ត្រីគេទៅជូនដំណើរដែរទេ?

យ៉នៈ ចាំ!ៗ

ណារឿនៈ សម្ដេច សី ហនុ គាត់ទៅជូនដែរអត់កាលហ្នឹង?

យ៉នៈ អត់ទេ ស្ដេចគេទៅជូនអី គ្រាន់ថាគេចេញមុខ ដូចថាប៉ាវមានខុះខាតអីមានគេឲ្យអ្នកធំៗគេជួយយើងទៅណា គេបន្ទុកបណ្ដាក់អញ្ចឹងណា ។ គ្រាន់តែដឹងថា សីហនុហ្នឹងគាត់ឲ្យទៅ ។

ណារឿនៈ គាត់អ្នកផ្ដល់បួកឲ្យ?

យ៉នៈ ចាំ!ផ្ដល់បួកឲ្យទៅ ។មិនដែលបានលុយពីផ្ទះទៅទេយើងអត់មានលុយផ្ញើទៅទេតែវាទៅអីខ្លួនឯងអីខ្លួនឯង ។

ណារឿនៈ ចុះពេលគាត់ទៅឆ្នាំ១៩៦០ហ្នឹងគាត់មានគ្រួសារហើយនៅ?

យ៉នៈ នៅទេ ។

ណារឿនៈ អាយុប្រហែលជាប៉ុន្មានដែរកាលហ្នុង?

យ៉នៈ អាយុប៉ុន្មានដប់ទេ អាសេងលី មិនទាន់២០ទេ ។

ណារឿនៈ នៅក្រោម២០អញ្ចឹង?

យ៉នៈ ចាំ! នៅក្រោម២០ ។

ណារឿនៈ គាត់មានផ្ដាំផ្ញើអីថាម៉េចអត់ពេលគាត់រៀបឡើងយន្តហោះទៅ?

យ៉នៈ អត់មាននិយាយអីទេគ្រាន់តែថាប្រាប់រឿងគ្រួសារទេណា ពេលឡើងយន្តហោះប្រាប់ខ្ញុំថាឲ្យខ្ញុំចិញ្ចឹមម៉ែទៅ គាត់ចិញ្ចឹមពុក ចែកគ្នា ។

ណារឿនៈ ម៉េចអញ្ចឹង?

យ៉នៈគាត់ខឹងម៉ែគាត់ថាឯងនៅឯងមើលម៉ែណាំបងទៅបងចិញ្ចឹមឪពុកមកវិញចិញ្ចឹមឪពុកខឹងម៉ែ ៗមានប្ដី ។ ខឹងម៉ែគាត់មានប្ដីទៀត ។

ណារឿនះ គាត់មានគ្រួសារមួយទៀត?

យនះ មានមួយទៀត បើថាមួយពួកខ្ញុំមានតែពីរនាក់ទេស្រីមួយប្រុសមួយ តែថាយើងដាក់ទៅ យើងអាណិតប្អូនកុំឲ្យថាឪក្រោយឪចាស់ ខ្ញុំសាច់មួយដូចបង្កើតនឹងគ្នាអញ្ចឹងខឹងម្ដាយមានប្ដី គាត់ទៅស្រុកបារាំងខឹងដោយសាម៉ែមានប្ដីទេ កុំអីមិនទៅទេ នៅធ្វើការស្រុកខ្មែរហើយ គាត់ថាទៅឲ្យផុតទៅខ្មាស់គេ ។

ណារឿនះ

អញ្ចឹងអ៊ំកាលគាត់ឡើងយន្តហោះទៅដល់បារាំងអី ហើយហ្នឹងគាត់ដែលមានផ្ញើសំបុត្រ អីមកសួរសុខទុក្ខដែរអត់?

យនះ ផ្ញើ ចាំ! ផ្ញើ ៗ ផ្ញើថាឲ្យខ្ញុំខំរៀនឡើងព្រោះយើងដូចថាម្ដាយមានប្ដីក្រែងលោគេធ្វើបាបអី ខ្ញុំខំប្រឹងឡើងឲ្យមានចំណេះវិជ្ជា ដូចថាចំណោះវិជ្ជាហ្នឹងហើយដែលឲ្យយើងថ្កើនអ្ហាស់ ចេះតែសរសេរមកប្រាប់ប្អូនអ្ហាស់ ហើយវាក៏អត់មានលទ្ធភាពអីមកជួយយើងអ្ហាស់ វាអត់ទាន់មានអ្ហាស់ ឲ្យវាជួយខ្លួនវាឲ្យធំសិនអានេះណាំ តែអកុសល្យវាអញ្ចឹងអ្ហាស់ អត់បានជួបគ្នារហូតណាំ អត់មានបានជួបទេបានតែឮយើងឆ្លើយឆ្លងដល់យើងនិយាយរឿងខ្មែរក្រហមឡើងបាត់រហូតអត់ឮដំណឹង បាត់រហូតទាល់តែឮដំណឹង នួន ជា គេឲ្យដំណឹងទេ ៗ នួន ជា ណាឲ្យដំណឹងមិននិយាយលេងទេកាលអាពតហ្នឹង ខ្ញុំនៅព្រែកនរិននេះ នួន ជា គេឲ្យប្អូនគេទៅគយអ្ហាស់ មិនមែនគយទេ មារ៉ឺខ្ញុំហ្នឹង គយដែរតែមិនដឹងថាគយយ៉ាងម៉េចមិនដឹងទេ ចេញទៅគេបើកឡានខ្មែរក្រហមប្អូនគេបង្កើតនោះ ប្អូនបង្កើត នួន ជា ។

ណារឿនះ ប្អូនបង្កើតនួន ជា ឈ្មោះអីគេដែរ?

យនះ ឈ្មោះ រ៉ឺ តែមិនដឹង ដែង រ៉ឺ អី? កូនគេនៅសន្ទឹកណាស់នៅវត្តគរទាំងអស់ ។

ណារឿនះ នៅហ្នឹងដែរអ្ហែស?

យនះ ចាំ! មារ៉ឺ មិនដឹងជាឈ្មោះអី រ៉ឺ? ដែង ហើយដឹងថាត្រកូលដែងហើយ មិននិយាយនួន ជា ទេគេមានប្ដីណោះគេយកត្រកូលឪគេ ។

ណារឿនៈ ឈ្មោះអីដែល វ៉ី ?

យនៈ ឡាវ ស្អី វ៉ី ទេ ឪពុកខ្មែរ ឡាវ ។ ព្រោះគាត់ឪគាត់ចិន គាត់ខ្មែរឡាវ តែមិនដឹងស្អី វ៉ី ទេ តែ វ៉ី ៗ ហើយ ។

ណារឿនៈ នួន ជា គាត់ឈ្មោះ អី ឡាវ ឪម៉េច?

យនៈ ទេអត់ទេ ។

ណារឿនៈ ឈ្មោះវ៉ី?

យនៈ ចា៎!

ណារឿនៈ សព្វថ្ងៃគាត់មានបងប្អូនគាត់នៅ ...?

យនៈ គាត់បងប្អូនសុទ្ធតែនៅអាមេរិកណាក កូនគាត់អីសុទ្ធតែនៅអាមេរិកណាក ។

ណារឿនៈ វ៉ី ហ្នឹងអ្នែស?

យនៈ ចា៎! តែគាត់ខូចហើយ ។

ណារឿនៈ មានបងប្អូនគាត់នៅភូមិវត្តគរនេះដែរទេ?

យនៈ កូនគាត់នៅសន្ទឹកណាស់ កូនសុទ្ធតែប្ដីគេធំៗណា៎ ។

ណារឿនៈ នៅភូមិ...?

យនៈ ភូមិវត្តគរ នៅផ្ទះម៉ែគាត់ហ្នឹង ។

ណារឿនៈ ឃុំអីដែរ?

យនៈ ឃុំវត្តគរហ្នឹង ។

ណារឿនៈ ភូមិវត្តគរ ឃុំវត្តគរ ។ ប្រពន្ធគាត់នៅដែរអត់?

យនៈ ព្រពន្ធនៅអាមេរិកណាក ។

ណារឿនៈ ទៅអាមេរិកបាត់ហើយ ។

យនៈ ចា៎! ចេញទៅតាមកូន ។

ណារឿនៈ ចុះបងប្អូនរបស់តា វ៉ី ហ្នឹង?

យន៖ នៅអ៊ីមួយទៀត អ៊ី ហ៊ិចគាត់ខូចហើយ អ៊ីគ្រឿតគាត់ខូចហើយ ឥឡូវខ្ទិននៅផ្ទះ ។ ចាស់ៗអស់ហើយ ប្អូនស្រីក៏នៅអាមេរិកដែរ ប្អូនស្រី ។

ណារឿន៖ អ៊ុំអី?

យន៖ យាយគ្រឿត ។

ណារឿន៖ គាត់ត្រូវជាយ៉ាងម៉េច?

យន៖ ប្អូនបង្កើត នឹងនួន ជា ហ្នឹង ចា៎! ប្អូនបង្កើត នួន ជា ហើយ ។ ខ្ញុំហៅអ៊ុំ ហៅពូអ្នកស ។

ណារឿន៖ ឈ្មោះ គ្រឿត ។

យន៖ ចា៎! ត្រកូលឡាវ ហើយ តែមិនដឹងឡាវអី ។

ណារឿន៖ គាត់នៅភូមិណាដែរ?

យន៖ វត្តគរជាមួយគ្នាហ្នឹងនៅសព្វថ្ងៃហ្នឹង ។

ណារឿន៖ គាត់ចាស់ហើយ?

យន៖ ចាស់ហើយ៧០ប្លាយ ជិត៨០ ហើយ ដើរអត់រួចផង ។

ណារឿន៖ មានពីណាទៀតអត់ត្រូវជាសាច់ញាត្តិបងប្អូនតានួនជានៅម្តុំវត្តគរហ្នឹង គេស្គាល់ច្រើន តែម្តងស្អែសនៅម្តុំវត្តគរហ្នឹង បើយើងទៅសួរ ។

យន៖ ទៅដល់នៅពេញហ្នឹងទាំងអស់តែថានួនជាសព្វថ្ងៃហៅខ្ញុំទៅជួបក៏ខ្ញុំមិនដែលទៅដែរ ខ្ញុំស្អប់តាំងពីអាពតហ្នឹងមកខ្ញុំមិនឲ្យជួបមុខខ្ញុំតែបងប្អូនក៏ខ្ញុំមិនរវីរវល់ដែរ អត់សោះខ្ញុំអត់ទាក់ទងសោះ ។ គាត់មកវត្តគរញឹកដែរតើ មកលេងញឹកតើពេលនេះមកដល់ប្រាប់ថាឲ្យកូនខ្ញុំអីទៅលេង ខ្ញុំថាអត់ទេជួយយើងអត់ជួយ ទឹងណាគាត់អត់ជួយផង ។

ណារឿន៖ បាទ! ចាំបន្តិចទៀតខ្ញុំសួរទាក់ទងរឿង នួន ជា បន្តិចណា៎ ។ ឥឡូវខ្ញុំសួរបញ្ចប់រឿងអ៊ំសេងលីអ្នកស ។ កាលដែលគាត់ទៅស្រុកបារាំងហ្នឹងគាត់មានផ្ញើសំបុត្រអីមកច្រើនដែរ ឆ្លើយឆ្លងគ្នាជាមួយអ៊ំ?

យន៖ ចា៎!

ឆ្លើយឆ្លងគ្នាយូរដែរដល់អារឿងដែលយើងថាពីរឿងគេផ្ញើសំបុត្រមកពួកម៉ាកហ្នឹង

ថាអារឿងចូលក្រហមហ្នឹង ថាកុំចូលក្រហមដល់វាចូលក្រហមវាឈប់ទាក់ទងជាមួយយើងទៅ ។

ណារឿនៈ អ៊ុំកាលដែលគាត់ផ្ញើសំបុត្រអីមកហ្នឹងភាគច្រើននិយាយពីអីដែរសំបុត្រគាត់?

យនៈ និយាយតែពីសួរសុខទុក្ខទេអត់មាននិយាយរឿងអីទេ ។

ណារឿនៈ គាត់អត់មាននិយាយថាគាត់នៅនោះធ្វើអី...?

យនៈ អត់និយាយ គ្រាន់តែសុខសប្បាយឲ្យយើងថែខ្លួនទៅ ចុះប្អូនស្រីតែមួយ ។

ណារឿនៈ ចុះទាក់ទងគ្រួសារគាត់រៀបការអីនៅហ្នុងនៅក្រៅហ្នឹង?

យនៈ អត់ទេ ។

ណារឿនៈ អត់មាននិយាយដែរ?

យនៈ អត់ ពួកម៉ាកគេទេអ្នកឲ្យដំណឹងថាអា សេងលី មានប្រពន្ធហើយ វាអត់និយាយទេរឿងប្រពន្ធ ។

ណារឿនៈ ពួកម៉ាកហ្នឹងឈ្មោះអីដែរអ៊ុំ?

យនៈ ឈ្មោះ ចៅ ប៊ុនឡុង ។

ណារឿនៈ ចៅ ប៊ុនឡុង ប្រាប់ថាសេងលីហ្នឹងមានប្រពន្ធហើយ?

យនៈ ចា៎! ជនជាតិស៊ុីសហើយមានកូនស្រីមួយប្រុសមួយ ។

ណារឿនៈ ប្រាប់ថាកូនហ្នឹងឈ្មោះអីដឹងដែរអត់?

យនៈ អត់ស្គាល់វាមិនឲ្យដឹងទេ វាមិនឲ្យដឹងថាមានប្រពន្ធដងហ្នឹង នេះតាមរយៈពួកម៉ាកអ្នាស់ ។

ណារឿនៈ អ៊ុំដឹងថាគាត់មានដំណឹងថាគាត់មានប្រពន្ធអីឆ្នាំណាដែរ?

យនៈ មិនទាន់នេះទេណា មិនទាន់ លន់ នល់ ទេពេលដែលគេគេមកប្រាប់ហ្នឹងណា ដល់ លន់ នល់ មានកូនប្រុសមួយស្រីមួយតែខ្ញុំអត់ដែលស្គាល់ទាក់ទងគ្នាទេ តែបើសួរអាឡាំងដាញ៉ែល ដឹង ។

ណារឿនៈ តែក្រោយមកពេលដែលអ៊ំដឹងថាគាត់មានប្រពន្ធអញ្ចឹងគាត់មានដែលផ្ញើរូបថតប្រពន្ធ កូនមកដែរទេ ។

យនៈ អត់ផ្ញើរូបថតអីទេផ្ញើតែសំបុត្រធម្មតាសួរតែសុខទុក្ខធម្មតា អត់និយាយរឿងអាហ្នឹង គឺអត់មាន ។

ណារឿនៈ អញ្ចឹងដឹងដំណឹងហ្នឹងដោយសារពួកម៉ាកគាត់ទេ?

យនៈ ចាំ! ដោយសាមិត្តភក្តិគាត់ទេ សុង គ្រី នៅអាមេរិក ។

ណារឿនៈ ចៅ ប៊ុនឡុង អ្ហែស?

យនៈ ចៅ ប៊ុនឡុង មួយ សុង គ្រី មួយ ។ ចៅ ប៊ុនឡុង នៅបារាំងទេ ។

ណារឿនៈ និងម្នាក់ទៀតឈ្មោះអីគេ?

យនៈ សុង គ្រី នៅអាមេរិក ។ គេតេមកសួរហើយ សួរខ្ញុំថាអាសេងលីអត់ឃើញនៅ នោះទេណា ខ្ញុំរកវាហើយរកអត់ឃើញទេណា៎ វាមកស្រុកខ្មែរអ្ហាស៎ ខ្ញុំថាដឹងហើយដឹងថាមកស្រុកខ្មែរហើយតែវាអត់ដឹងដំណឹងសោះ ។

ណារឿនៈ គាត់តេមកឆ្នាំណា?

យនៈ តេមកយើង ៨១, ៨២ ដែលយើងអន្ទះសារដើររកនោះ ដើរសួរគេគ្រប់គ្នាខ្ញុំដើរមើលហោរផង ដើរសួរគេផងហើយប្រាប់ថាបើចូលគុកទួលស្លែងជួយមើលខ្ញុំផងខ្ញុំអត់ហ៊ានទៅ ឮថាទារុណកម្មហ្នុងខ្លាំងណាស់មើលទៅ ខ្ញុំថាខ្ញុំអត់ហ៊ានទៅទេ ។

ណារឿនៈ អ៊ុំខ្លាចរន្ធត់អ៊ុំ អ្ហែស?

យនៈ ចាំ! ខ្ញុំខ្លាចខ្ញុំអត់ចូល ខ្ញុំឲ្យគេរកគេថាមិនឃើញទេ អាសេងលីមិនមែនងាប់នៅហ្នឹងទេ ។

ណារឿនៈ អញ្ចឹងអ៊ុំរយៈពេលដែលគាត់ទៅ បើគិតទៅវា១០ឆ្នាំដល់ឆ្នាំ៧០ រដ្ឋប្រហារអ្ហាស៎
អ៊ុំឆ្លើយឆ្លងសំបុត្រជាមួយគាត់គាត់នៅបារាំងរហូត
ឬគាត់ផ្លាស់ទៅប្រទេសណាផ្សេងទៀត?

យនៈ	អត់ទេនៅ បារាំង ដែលឆ្លើយឆ្លងគ្នា ដល់អាក្រោយដែលបាត់ដែលខ្ញុំថារឿងក្រហមអី ហ្នឹង បាត់គឺអត់មានឈប់ទាក់ទង ។

ណារឿនៈ	ឆ្នាំណាអ៊ុំដឹងថាគាត់ចូលខាងក្រហម?

យនៈ	អត់ចាំទេ ។

ណារឿនៈ	ដែលបាត់ដំណឹងពីគាត់តែម្តងនៅឆ្នាំណារដ្ឋប្រហារហើយនៅ ៧០ ?

យនៈ	ដែលបាត់ដំណឹងចូល៧០ ហើយ យូរដែរហើយ ។

ណារឿនៈ	មុនឬក្រោយ?

យនៈ	ដូចមុន ។

ណារឿនៈ	បាត់ប៉ុន្មានឆ្នាំបានដល់រដ្ឋប្រហារ?

យនៈ	បាត់យូរដែរមិនបានដឹងទេណា ។

ណារឿនៈ	អ៊ុំដឹងថាគាត់ចូលក្រហមហ្នឹងពីណាគេប្រាប់អ៊ុំដែរ?

យនៈ	វ៉ាន់ ដេត ហ្នឹងសុទ្ធតែជំនិតគេហើយ តែគេអត់ចូលទេ គេអត់មកឯណាពួកហ្នឹងនៅ រស់ទាំងអស់ គាត់ឆ្លុតម្នាក់ឯង ។

ណារឿនៈ	ឈ្មោះវ៉ាន់ ដេត អ៊ុំអ្នែស?

យនៈ	ចា៎!

ណារឿនៈ	គាត់ប្រាប់ថាសេងលីហ្នឹងគាត់ចូលក្រហមហើយ?

យនៈ	ចា៎!

ណារឿនៈ	គាត់មាននិយាយប្រាប់ថាអ៊ុំ សេងលីហ្នឹងគាត់ចូលខាងក្រហមអីដែរអត់?

យនៈ	ខ្ញុំដូចថាខ្ញុំក្មេងខ្ញុំអត់សូវទំនាក់ទំនងច្រើន ព្រោះពួកម៉ាកបងប្រុសអីបើកាលណាគេមាន ការសំខាន់បានគេប្រាប់យើង ហើយរឿងពីដើមយើងអត់សូវទាក់ទងគ្នា ។

ណារឿនៈ	វ៉ាន់ ដេត ដែលប្រាប់អ៊ុំហ្នឹង គាត់នៅ រៀនជាមួយអ៊ុំ សេងលី ហ្នឹងដែរអត់ទេ?

យនៈ	ទេ នៅអាមេរិកទេ ។

ណារឿនៈ	គេនៅអាមេរិក ម៉េចបានដឹង?

យន៖ ដំនិតពួកម៉ាកគេ ។

ណារឿន៖ ពេលគាត់ប្រាប់អ៊ុំហ្នឹងគាត់ប្រាប់នៅសម័យខ្មែរក្រហមឬក្រោយទេ?

យន៖ អត់ទេប្រាប់មុន ដែលចូលក្រហមហ្នឹងចូលមុន ។

ណារឿន៖ ចុះគាត់នៅអាមេរិកម៉េចគាត់ប្រាប់អ៊ុំកើតពេលហ្នឹង?

យន៖ មិនដឹងដែរពេលហ្នឹង តែគេចេះតែឲ្យដំណឹងមកអញ្ចឹងគ្រាន់តែថាដឹងគេហ្នឹងនៅរៀន ដែលខ្ញុំខស្ទរាទៅទាក់ទងសាលាគេពីដើមស្គាល់ទាំងអស់ ខ្ញុំប្អូនអញ្ចឹងអ្ហាស៎ មានការអី គេទាក់ទងឲ្យយើងដឹង តែរឿងអ្វីផ្សេងគេអត់និយាយទេ គ្រាន់តែថាគេ អាសេងលី ដើរផ្លូវខុសហើយ គ្រាន់តែគេប្រាប់អញ្ចឹងណា ។

ណារឿន៖ អញ្ចឹងកាលដែលអ៊ុំដឹងដំណឹងថាគាត់ចូលក្រហមហ្នឹង ពួកម៉ាកគាត់ឈ្មោះ វ៉ាន់ ដេត ហ្នឹងប្រាប់អ៊ុំ ពេលដែលប្រាប់ហ្នឹងគាត់នៅណា?

យន៖ នៅបារាំង បើសុង គ្រី បាននៅអាមេរិក ។ វ៉ាន់ ដេត សព្វថ្ងៃនៅបារាំងដែរ ដល់ដឹងរឿងចិន បានប្រពន្ធចិនអីដឹងអាពតនេះ ។ ដឹងតាមអ្នកវត្តគរប្អូនថ្លៃរបស់ នួន ជា ដែលប្តីចងកសម្លាប់ខ្លួននៅផ្ទះលោក ក កន្លែងក្តាន់ហ្នឹងណា ចងកសម្លាប់ខ្លួនដែលខុស ហ្នឹងណា វាជ្រុលអានេះដូចថាក្រហមជ្រុលអ្ហាស៎ ចងកសម្លាប់ខ្លួនតើ ។

ណារឿន៖ ខ្ញុំនៅតែឆ្ងល់វ៉ាន់ដេហ្នឹងគាត់នៅបារាំងដែរកាលហ្នុង ហើយអ៊ុំនៅស្រុកខ្មែរទេកាលហ្នុងចុះគាត់ផ្ញើដំណឹងតាមណាមកកាលហ្នុង?

យន៖ បុស្តិ៍ ។

ណារឿន៖ តាមបុស្ដិ៍ តាមសំបុត្រអ្នែស?

យន៖ ចា៎! អត់មានទូរសព្ទ័ឯងណាយើងពីដើមតាមបុស្តិ៍ បងប្រុសខ្ញុំក៏ផ្ញើរតាមបុស្តិ៍ដែរ ហើយដែលថាយើងដឹងដំណឹងថាគាត់បានប្រពន្ធនារីវាយម៉េងប៉ុងលេខមួយស្រុកចិន ហ្នឹងក៏ដោយដាម្តាយមីងគាត់មកពីចិនហ្នឹងណា គាត់មកពីចិនហ្នឹងគាត់មកនៅ គាត់ក្រហមដែរគាត់មកនៅនេះ នៅផ្ទះលោក ក នេះ

តែគាត់មកមានកូនប្រុសកូនស្រីគាត់

មកមួយគ្រួសារតែយើងមិនដឹងស្អីចឹងកសម្លាប់ខ្លួនទៅ ។

ណារឿនៈ គាត់ចឹងកម្នាក់ឯង?

យនៈ ចា៎! ប្ដី ។

ណារឿនៈ ប្ដីគាត់ឈ្មោះអី?

យនៈ ទាល់តែម៉ែបានស្គាល់ខ្ញុំអត់ស្គាល់ទេ។គាត់ គន មិនដឹងជា គន ស្អី ឈ្មោះ គន ហើយនៅចិន គាត់មកយកប្រពន្ធគាត់ទៅ ពីស្រុកខ្មែរទៅណា គន ហ្នឹងបាត់ដំណឹងយូរហើយ ស្រាប់តែថាឮដំណឹងមុន មិនមែន លន់ នល់ ទេមុន លន់ នល់ អ្ហាស៎ ។ មុន លន់ នល់ ដែលយើងស្រុកស្រួលហ្នឹង គេមកយកប្រពន្ធគេទៅស្រុកចិនទៅ ។

ណារឿនៈ សម័យសង្គមរាស្ត្រនិយមអ្ហែស?

យនៈ ចា៎! សង្គមរាស្ត្រនិយមហ្នឹងគេមកយកប្រពន្ធគេបានទាំងអស់ទៅ ។

ណារឿនៈ

ពេលដែលថាដឹងដំណឹងថាគាត់ចូលក្រហមហើយអញ្ចឹងគាត់ឈប់ផ្ញើសំបុត្រមកអ៊ុំតែម្ដង អ្ហែស?

យនៈ អត់ ៗផ្ញើ ។

ណារឿនៈ ចុះអ៊ុំមានផ្ញើសំបុត្រទៅសួរសុខទុក្ខគាត់ដែរអត់?

យនៈ អត់ ។

ណារឿនៈ តែកាលមុនឆ្លើយឆ្លងគ្នា?

យនៈ ឆ្លើយ ដល់បាត់ទៅ យើងអត់ដឹងថាគេនៅណាយើងផ្ញើម៉េចកើត ។

ណារឿនៈ យើងអត់ដឹងអាសយដ្ឋានគេនៅណាអ្ហែស?

យនៈ ចា៎!

ណារឿនៈ ចុះពេលអ៊ុំដឹងដំណឹងថាគាត់ចូលក្រហមអញ្ចឹងគ្រួសារអ៊ុំនៅផ្ទះគិតយ៉ាងម៉េចដែរ?

យនៈ មិនអាចគិតយើងនៅក្នុងគ្រួសារយើងនេះគឺអត់អាចទេ ព្រោះអាឡែងតែខ្វល់អារឿងរស់ ។

ណារឿនៈ ចង់ឲ្យគាត់ចូលក្រហមដែរអត់កាលហ្នឹង?

យនៈ អត់ទេ ហាមដែរតែដល់យើងហាមពេកគេឈប់ទាក់ទង ហើយដល់ពេលខ្មែរក្រហមចូលមកនេះបានយើងដឹងដំណឹងថាគាត់ហ្នឹងមានប្រពន្ធនារីវាយប៉េងប៉ុងហ្នឹងណា ពីមុនមកយើងអត់ដឹងទេ ។

ណារឿនៈ ពេលឆ្នាំណាអាហ្នឹងឆ្នាំ ៧៥ ហើយនៅ?

យនៈ ទេខ្មែរក្រហមមកនៅហើយហ្នឹង ។

ណារឿនៈ រដ្ឋប្រហារហើយហើយ ។ រដ្ឋប្រហាប្រហែលជាប៉ុន្មានឆ្នាំដែរ?

យនៈ ខ្មែរក្រហមចូលបានប៉ុន្មាន វាមិនចាំផង ។

ណារឿនៈ បែកភ្នំពេញហើយនៅ?

យនៈ បែកហើយ គេបែកហើយបានគេប្រាប់ថា...

ណារឿនៈ ចូលឆ្នាំខ្មែរ ១៧មេសា ។

យនៈ គេប្រាប់ថាវាមានប្រពន្ធចិនហើយ ។

ណារឿនៈ ដឹងតាមរយៈពីណាគេថាគាត់មានប្រពន្ធចិនហ្នឹង?

យនៈ អ៊ុំ គ្រឿតណា អស់មិនមែនទេ ម៉ែអានេះអ្នាស៎ អ៊ុំល្មឿត ។

ណារឿនៈ អ៊ុំល្មឿត ?

យនៈ ចា៎!

ណារឿនៈ ត្រូវជាយ៉ាងម៉េចនឹងអ៊ុំដែរ?

យនៈ អត់ទេខ្សែវត្តគរទាំងអស់ ។

ណារឿនៈ ខ្សែខាងតាជាដែរ?

យនៈ ចា៎! ខ្សែខាងហ្នុងទាំងអស់ ។

ណារឿនៈ ដឹងថាគាត់មានប្រពន្ធចិន?

យនៈ ចាំ! មានកូនប្រុសមួយស្លាប់ស្រុកខ្មែរ ។

ណារឿនៈ ឈ្មោះអីដែរប្រពន្ធគាត់?

យនៈ អត់ដឹងទេ ។

ណារឿនៈ មានកូនប្រុសប៉ុន្មាននាក់?

យនៈ មានមួយ មានតែមួយហ្នឹងតែស្លាប់ស្រុកខ្មែរ ។

ណារឿនៈ ធ្វើម៉េចអ៊ុំដឹងថាស្លាប់នៅស្រុកខ្មែរ?

យនៈ គេហ្នឹងហើយគេប្រាប់ គេថាកូនហ្នឹងអត់បានរស់ទេ កូនហ្នឹងឈឺ ។

ណារឿនៈ អាយុប្រហែលជាប៉ុន្មានបានស្លាប់?

យនៈ ខ្ញុំអត់បានសួរផង អត់បានសួរទេ ។

ណារឿនៈ ដោយសាឈឺ ។

យនៈ ចាំ! ថាឈឺស្លាប់ដោយឈឺ ។ ពេលហ្នឹងប្រពន្ធគេហ្នឹងចិនសុទ្ធគេមកស្រុកខ្មែរដែរហ្នឹង គេមកជួយប្រទេសជាតិដែរហ្នឹង ។

ណារឿនៈ មកស្រុកខ្មែរហ្នឹង?

យនៈ ចាំ! មកមុនប្ដីផង ។

ណារឿនៈ ប្រពន្ធហ្នឹងថាជាអ្នកវាយប៉េងប៉ុងអ្វែស?

យនៈ ចាំ! លេខមួយស្រុកចិនអ្នាស់ ។ បែបគេធ្វើធំហើយដែរដឹងយើងអត់ដឹងគេអ្នាស់ តែគេចូលបក្សក្រហមយើងអត់ដឹងគេធ្វើអី យើងអត់ដឹងរឿងដាច់ ។

ណារឿនៈ គាត់មកស្រុកខ្មែរដែរប្រពន្ធហ្នឹង?

យនៈ ចាំ! មកមុនប្ដី តែមកអត់បានជួបគ្នាទេ ។

ណារឿនៈ មកពេល៧៥បែកភ្នំពេញហ្នឹង?

យនៈ មកពេលបែក៧៥ហ្នឹងណា ។ ប្ដីមក៧៦ ៧៦ហ្នឹងគេធ្វើដំណឹងថាអា សេងលី មកហើយ ។

ណារឿនៈ អញ្ចឹងដល់៧៦ បានដឹងថា...

យនៈ ចា៎! ដឹងថាវាមកហើយចុះនៅព្រែកអញ្ចាញ អង្គរគេថាឲ្យជួយយកផងព្រោះគេធ្វើធំ អ្នកស៊ាស់ថាឲ្យជួយក្ខួយផង ។ គាត់ថាអត់ទេអត់និយមទេ មិនអាចនិយមបានទេ ។

ណារឿនៈ កាលហ្នឹងម្ដាយអ៊ុំគាត់ទៅសុំតា នួន ជា ដល់ផ្ទះអ្វែស?

យនៈ អត់បើបានទៅដល់ផ្ទះគេរស់នៅផ្ទះគេបាត់ហើយគេទទួលហើយ ព្រោះគ្រាន់តែឲ្យដំណឹងអ្នកស៊ាស់ប្អូនគេបើកឡានខ្មែរក្រហមអាគយហ្នឹដល់នេះគេមិនសម្លាប់ឯណាសាច់ឈាមគាត់គេមិនសម្លាប់ឯណា គេឲ្យបើកឡានដឹកស្បៀង ដឹកទៅដល់ក្រោមផ្ទះខ្ញុំឯណាកខ្ញុំជម្លាសទៅខ្ញុំចុះទៅតាមមាត់ស៊ឺផ្សារលើទៅ ១២គ្រួសារផ្សារលើទៅនៅព្រែកនរិនទាំងអស់គ្នា ។

ណារឿនៈ អញ្ចឹងដឹងដំណឹងមកថាគាត់ចុះនៅព្រែកអញ្ចាញ?

យនៈ ចា៎! ចុះនៅព្រែកអញ្ចាញ ។

ណារឿនៈ ពីណាគេអ្នកប្រាប់ដំណឹងហ្នឹង?

យនៈ មារ៉ី ហ្នឹង ។

ណារឿនៈ ប្រុសឬស្រី?

យនៈ ប្រុស គាត់ធ្វើកយហ្នឹង ។

ណារឿនៈ គាត់ធ្វើកយ លន់ នល់ អ្វែស?

យនៈ ទេ ធ្វើកយសី ហនុ គាត់ធ្វើតាំងពីដើមមក តែមិនបានមេទេ អនុប្រធានអីហ្នឹង តែមានណាស់ ។

ណារឿនៈ គាត់ត្រូវយ៉ាងម៉េចនឹងតា នួន ជា?

យនៈ ប្អូន បង្កើត ។

ណារឿនៈ ឥឡូវគាត់ស្លាប់បាត់ហើយ?

យនៈ ស្លាប់ហើយ ។

ណារឿនៈ ចុះក្រោយមកទៀតពេលដំណឹងថាអ៊ុំសេងលីគាត់ចុះនៅព្រែកអញ្ចាញ គ្រួសារខាងឪពុកម្តាយអ៊ុំនេះធ្វើម៉េចដែរ?

យនៈ អត់.....

## ចប់សាយអេ កាសែ្សតទីមួយ

ណារឿនៈ អត់មានប្រាប់គេថាបងមកអីអញ្ចឹងទៅលេងបងទេ?

យនៈ អត់ទេអត់ហ៊ានទេ ។

ណារឿនៈ ចុះម្តាយអ៊ុំ?

យនៈ បេះតែពីឃុំទៅមាននេះអី ថាចង់ឃើញមុខកូនបន្តិចឲ្យគាត់ស្លាប់ក៏គាត់ព្រមដែរណា ហើយដល់យើងយួនចូលនេះទៀត ដើរមើលហោរ គេថាសូន្យហើយ ។

ណារឿនៈ ចុះអ៊ុំថាទៅជួបតា នួន ជា ម៉េចថាឲ្យគាត់ជួយម៉េច?

យនៈ ផ្ញើដំណឹងតាមប្អូនគាត់ទៅ ។

ណារឿនៈ ផ្ញើតាមតាវ៉ី ហ្នឹងស្អែស?

យនៈ ចាំ! ប្រាប់ថាឲ្យឪពុកមាហ្នឹងជួយផង ឲ្យជួយយកបងប្រុសមក ម្តាយខ្ញុំគាត់ប្រាប់ថាឲ្យជួយយកកូនប្រុសហ្នឹងមកផង ។

ណារឿនៈ បើនិយាយពីទំនាក់ទំនងទៅម្តាយរបស់អ៊ុំនិងតា នួន ជា ត្រូវជាយ៉ាងម៉េចដែរ?

យនៈ បងប្អូន ។

ណារឿនៈ បងប្អូនដែរ ជីដូនមួយក៏...?

យនៈ មិនមែនជីដូនមួយទេ អានេះស៊ីខ្សែគ្នាម៉េចមិនដឹងទេ ព្រោះថាជិតដិតនឹងគ្នាណាស់ ម្តាយ នួន ជា នៅតែផ្ទះខ្ញុំផ្សារលើហ្នឹង ។ ម្តាយ នួន ជា នៅតែហ្នឹងឯង ។

ណារឿនៈ នៅផ្សារលើហ្នឹង?

យនៈ ចា៎! ផ្ទះគាត់នៅវត្តគរតែមកនៅហ្នឹងវាល់ៗល្ងាច មកធ្វើអីទទួលទានម្ដាយខ្ញុំគាត់ចេះធ្វើម្ហូប គាត់នោះមេចុងភៅម្ដាយ នួន ជា ហ្នឹងមេចុងភៅ គាត់ចុងភៅស្ដេចណា ។

ណារឿនៈ គាត់ឈ្មោះអីដែរម្ដាយចុងភៅកាលហ្នុង?

យនៈ ឈ្មោះពេញ ។

ណារឿនៈ អត់ដឹងឈ្មោះពេញអីដែរ?

យនៈ អត់ដឹងទាល់តែម្ដាយខ្ញុំ ហៅម៉ាពេញៗ ។

ណារឿនៈ គាត់ចុងភៅអ្ហ៊ែស?

យនៈ ចា៎! គាត់ធ្វើក្រយ៉ាស្ដេចណា៎ ។

ណារឿនៈ អញ្ជឹងទំនាក់ទំនងគាត់ជាមួយម្ដាយអ៊ុំជិតស្និតហើយ អត់អាចជួយបានដែរកាលហ្នុង?

យនៈ ជិតស្និតតែគាត់ថាដូចតុក្កតាដែរ ស្រេចតែកូនចាត់ចែងគាត់មានហ៊ានអី មិនហ៊ានទេ ដល់យួនចូលមកហ្នឹងសម្លាប់អស់គ្រួសារហ្នឹងច្រើនដែរ ។

ណារឿនៈ ចុះដូចថាពេលគាត់ម្ដាយអ៊ុំគាត់ផ្ដាំដំណឹងតាម តារ៉ី ទៅប្រាប់អញ្ជឹង តានួន ជា ឆ្លើយថាម៉េចទៅ?

យនៈ គាត់ថាមិនអាច មិនអាចជួយបានទេ ។

ណារឿនៈ គាត់មានប្រាប់ថាហេតុអីដែរអត់?

យនៈ គាត់ថាគេអត់និយម ។

ណារឿនៈ គេអត់បក្សពួកនិយមទេ?

យនៈ ចា៎! ៗប្រាប់ថាគាត់អត់ហ៊ានទេ ដូចថាធ្វើអញ្ជឹងខុសច្បាប់អ្ហាស៎ ដូចថាខ្លួនឯងមកបានមក រត់មកបាន មក យើងរត់មិនបាន យើងទៅទាក់ទងអីកើត ព្រែកអញ្ចាញហើយ យើងនៅនេះទៅទាក់ទងណារួច ។

ណារឿនៈ ពេលអញ្ចឹងអ៊ុំដឹងថាមូលហេតុអីបានគាត់រត់មកស្រុកខ្មែរដែរអត់?

យនៈ អត់ដឹង ពូតែពួកគេនិយាយប្រាប់ថាមកជួយស្រុកខ្មែរ ។

ណារឿនៈ ចុះមកជួយអញ្ចឹងម៉េចបានគេចាប់?

យនៈ អត់ដឹង ពូថានិយាយថាមកជួយអញ្ចឹងបានចេះតែឆ្ងល់ថាម៉េចបានដាសាប់អញ្ចឹងណា ។ យើងមិនអាចទាក់ទងនិយាយគ្នាបានឲ្យផ្ទាល់មាតបានតែផ្ដាំផ្ញើ ។ យើងអត់ដឹងអ្វាស់ ។ បើខ្ញុំអត់ទាំងស្គាល់ផងព្រែកអញ្ចាញនៅណាខ្ញុំមិនស្គាល់ផង ព្រែកអញ្ចាញនៅណា ខ្ញុំនៅស្រុកខ្មែរមែនតែខ្ញុំមិនមែនអ្នកដើរ មិនដឹងព្រែកអញ្ចាញនៅណា គេថាភ្នំពេញ ក៏ភ្នំពេញនឹងគេទៅមិនដឹងស្អីទេដល់ឥឡូវនេះដើរសួគេព្រែកអញ្ចាញនៅណា ដល់គេថា អើហ្នឹងទៅ ក៏មិនដែលបានទៅដែរ ។

ណារឿនៈ ដល់អញ្ចឹងពេលគាត់ត្រឡប់មកឆ្នាំ៧៦ហ្នឹងមានដឹងដំណឹងតាមមិត្តភក្ដិគាត់ ឬតាមពីណា ថាគាត់ត្រឡប់មកហ្នឹងជួបប្រពន្ធគាត់កូនគាត់ដែរអត់?

យនៈ អត់មិនមានស្គាល់ពីណាទៀតទេនៅកន្លែងខ្មែរក្រហមហើយគឺចបចប់នៅតំបន់៤ហ្នឹងហើយ ខាងក្រោមហ្នឹងណាអត់មានដឹងទេ តាធ្លាប់ទៅផ្ទះម៉ាំពេញមួយដង អាប្អូនខ្ញុំពេទ្យ ស្ដៅហ្នឹងក៏ទៅដែរ ។

ណារឿនៈ ទៅធ្វើអីដែរ?

យនៈ ទៅសុំគេឲ្យជួយហ្នឹងណាព្រោះថាម្ដាយខ្ញុំគាត់យំពេខ្ញុំហ៊ានប្រើប្ដីទៅ តែប្ដីមុខសញ្ញា គេមករើផ្ទះនៅបាត់ដំបងនេះបានទៅដល់គាត់បាន គេឲ្យចេកឲ្យដូងមួយបាវទៅ អរចង់ ស្លាប់ ។

ណារឿនៈ អ៊ុំដូចថាពេលតាគាត់ទៅសុំអញ្ចឹងហើយ ប្អូនអ៊ុំទៅទៀតទៅសុំយាយពាញហ្នឹងអ្វែស?

យនៈ ចា៎! ហ្នឹងហើយឲ្យគាត់ជួយ ។

ណារឿនៈ នៅតែអត់បានទៀត?

យនៈ គាត់ថាគាត់អត់ហ៊ាន គាត់អត់ហ៊ាននិយាយអីជាមួយកូនផ្ដេសផ្ដាស់ទេគាត់អត់ហ៊ានទេ គាត់ថាគាត់ដូចតុក្កតាអញ្ចឹងអ្ហាស៎ គាត់មិនអាចនិយាយអីបានទេ ហើយគាត់គំរូវឲ្យគាត់ពិសាគាត់មិនមានដឹងថាស្អីទេយកស្អីឲ្យគាត់ពិសាគាត់ចេះតែពិសាទេចង់របស់ល្អអីមួយថ្ងៃស៊ីប៉ុន្មានពេលគឺរឿងរបស់គាត់កូនគេចាត់ចែងទេ គាត់អត់ដឹងទេ មិនអាចដឹងអីទាំងអស់ ។ គ្រាន់ថាទៅដល់ហើយគាត់អាចឲ្យអីវ៉ាន់ដែលគាត់មានរំលែកឲ្យយើងទទួលទានទៅណាដូចជាត្រីដូចជាផ្លែឈើអីមានដូងមានចេកមានអី ឲ្យយើងមានល្មត់អីឲ្យយើងតែបានតែមួយដងហ្នឹងទេ យើងមានដែលទៅទៀតឯណា ។ ប្រើគាត់ទៅគេមិនហ៊ានហើយយើងមានទៅទៀតឯណា ។

ណារឿនៈ បាត់ដំណឹងពីគាត់តាំងពីឆ្នាំហ្នុងមករហូត?

យនៈ ចា៎! បាត់រហូតរកផ្លូវរត់អត់រួច ។ ខ្ញុំចង់ទៅណាស់ម្ដាយខ្ញុំទាទៅ យំទាទៅណា៎ ជូនមកម៉េចកើតមានតែងាប់ៗទាំងអស់គ្នាហើយខ្ញុំអត់ស្គាល់ផ្លូវទេពីព្រែកនរិនមកផ្សារ ខ្ញុំអត់ស្គាល់ផង ទីងមោសុទ្ធ ហើយមិនដែលបានចេញទៅឃើញអីទេ ។

ណារឿនៈ អ្នកស្រុកផ្សារ?

យនៈ ចា៎! ផ្សារសុទ្ធ ។ ច្រូតស្រូវមួយថ្ងៃគេឲ្យខ្ញុំច្រូត១៥កណ្ដាប់ខ្ញុំធ្វើអត់កើត ខ្ញុំកូនខ្ចីនោះប្ដីខ្ញុំធ្វើការរួចទៅជួយច្រូតឲ្យតើលបៗពេលបាយលួចទៅជួយច្រូតរួចបានពរកូនមកផ្ទះ ។ ដល់ហើយដល់កំណត់ហើយតើ ដល់ក្រោយគេឲ្យទៅស្ទូងដកគេជួយទាំងអស់មិនឲ្យពិបាកទេ អ្នកទៅជាមួយគេជួយគេដឹងយើងអ្នកផ្សារសុទ្ធ ។

ណារឿនៈ អ៊ុំដូចថាពេលដែលគាត់ត្រឡប់ពីស្រុកចិនមកវិញពេល៧៦ហ្នឹងមិនមែនមកពីបារាំងទេមកពីចិន ។

យនៈ មកពីចិន ។

ណារឿនៈ អញ្ចឹងគាត់ចេញទៅស្រុកចិននៅឆ្នាំណាដែរ?

យនៈ អត់ដឹងបាត់ដំណឹងរហូតពេលដែលយើងហាមគេរៀនខ្មែរក្រហមហ្នឹង ។

ណារឿនៈ អញ្ចឹងវា១៥ឆ្នាំបាត់ដំណឹង ។

យ៉នៈ ទេទៅ បារាំងយើងទទួលដំណឹងបានយូរដែរតើ ដល់ពេលវាបែកឆ្វេងពេលយើងចុង ក្រោយ...

ណារឿនៈ ជិតរដ្ឋប្រហារ?

យ៉នៈ ចាំ! ព្រោះអាហ្នឹងមិនដឹងគេលអាម៉េចឲ្យត្រូវ ។ ពីមុនអត់ទេណាដាច់ខាត ម៉ែកុំព្រួយ ។

ណារឿនៈ គាត់ផ្ញើសំបុត្រមកថាដាច់ខាត?

យ៉នៈ ចាំ!ដាច់ខាតអត់ទេម៉ែកូនទៅ រៀនទៅ រកលុយឲ្យម៉ែ ឲ្យគ្រួសារមិនមែនទៅ ដើម្បីអីទេ មិនមែនទៅ ដើម្បីចូលបក្សនេះបក្សនោះទេវានិយាយដែរតើ ដល់វាធ្វើខុសវាអត់មាន ឲ្យដំណឹងយើងអ្នាស ។

ណារឿនៈ អ៊ុំថាដល់ពេលខាងគ្រួសារនេះប្រាប់ថាម៉េចកុំឲ្យចូលបក្សនេះបក្សនោះ ដល់ក្រោយមក អ៊ុំថាគាត់ខឹងយ៉ាងម៉េច ឈប់ផ្ញើមកអ្ហែស?

យ៉នៈ អត់ អានេះដូចថាអំពុលទុកអ្នាស យើងនិយាយដដែល ៗដូចថាខ្លួនគេ ៗ អាចដឹងខ្លួនគេ ហើយ

អានេះរៀនជ្រៅ ជ្រះស្រុកខ្មែរអត់មានថ្នាក់រៀនទៀតដងយើងចេះទៅ ប្រដៅ គេ អាហ្នឹងអញ្ចឹងណាំ ។

ណារឿនៈ ចុះអ៊ុំវិញពេលឆ្នាំ៧០ លន់ នល់ ធ្វើរដ្ឋប្រហារទំលាក់សម្តេច សី ហនុ ហ្នឹងអ្នាស ។ នៅផ្សារលើនៅ បាត់ដំបងយើងហ្នឹងមានខ្មែរក្រហមចូលមកហើយនៅ?

យ៉នៈ ទេកាលហ្នុងនៅ ទេអ្ហ ៧០អ្នាស?

ណារឿនៈ បាទ! កាលសម័យ លន់ នល់ អ្នាស ។

យ៉នៈ ពុំតែបាញ់គ្នា មិនទាន់ចេញមុខទេ ......... បើចូលមកក៏យើងអត់ស្គាល់ យើងមិនទៅ ដឹងមុខខ្មែរក្រហមយ៉ាងម៉េច ។ ដើរជាមួយគ្នា ។

ណារឿនៈ អញ្ចឹងពេលហ្នុងនៅផ្សារបាត់ដំបង លន់ នល់ កាន់ពេញតែម្តងអ្ហែស?

យ៉នៈ ពេញ ។

ណារឿនៈ ចុះរហូតដល់ឆ្នាំណាបានមានខ្មែរក្រហមចូលមក?

យនៈ ពេល៧៥ នេះពេញមែនទែនសម្រាប់ឲ្យយើងមើល ។

ណារឿនៈ អាពេលបែកភ្នំពេញហ្នឹងអ្ហែស? ពេលដែលជម្លាសប្រជាជនថ្មីមក?

យនៈ ចា៎! ខ្ញុំ៧៥ហ្នឹងបានគេជម្លាសដែរហ្នឹង ។

ណារឿនៈ ដូចថាអ៊ុំអ្នកស្រុកផ្សារអញ្ចឹងគេចាត់ទុកអ៊ុំថាប្រជាជនថ្មីដែរឬប្រជាជនចាស់?

យនៈ ទេចាស់ម៉េច ថ្មី ។ ទៅ នៅ គេថ្មី ។ ខ្ញុំកើតកូនបាន១២ថ្ងៃហើយ៧៥ជម្លាសហ្នឹងណា៎ ។

ណារឿនៈ ចុះពេលអ៊ំ នៅផ្សារលើហ្នឹងរបររកស៊ី ធ្វើអីដែរ?

យនៈ ខ្ញុំលក់ចាប់ហួយ ។

ណារឿនៈ តែនៅ រៀនដែរអត់កាលហ្នុង?

យនៈ ទេ ឈប់រៀនហើយ មានប្តីហើយ ។

ណារឿនៈ អ! នៅជាមួយតា ។

យនៈ ៦៧មានប្តីហើយ ។

ណារឿនៈ កាលអ៊ុំ នៅលក់ជាមួយតាអីហ្នឹងនៅជាមួយឪពុកម្តាយឬនៅផ្ទះផ្សេងគ្នា?

យនៈ ឪពុកម្តាយលែងគ្នា ឪពុកនៅឯស្រុកណេក ខ្ញុំនៅជាមួយម្តាយជុំគ្នា ។

ណារឿនៈ អញ្ចឹងយាយពាញ គាត់ខស្បាហ៍មកដែរអ្ហែស?

យនៈ ខស្បាហ៍មកតើ ។

ណារឿនៈ អ៊ុំស្គាល់មុខគាត់ច្បាស់ដែរអ្ហែស?

យនៈ ចុះបើនៅជាមួយគាត់ដែរហ្នឹង ទៅមកៗយើងផ្សារលើវត្តគរជិតគ្នាហ្នឹង ហើយគាត់មានការអីគាត់មកសំរាន់ពិសារបាយអីផ្ទះយើងហ្នឹង ។

ណារឿនៈ ប្តីរបស់យាយពាញ ហ្នឹងគាត់ឈ្មោះអីដែរ?

យនៈ មិនដឹងឡាវអីទេ ។

ណារឿនៈ តាហ្នឹងគាត់ខស្បាហ៍មកដែរទេ?

យនៈ គាត់ទៅស្រុកចិនយូរហើយ ចិនសុទ្ធ សិតតែប្តីចិនសុទ្ធហ្នឹង ។

ណារឿនៈ យាយពាញ ហ្នឹងប្ដីគាត់ចិនសុទ្ធដែរ?

យនៈ ចិនសុទ្ធដែរហ្នឹង ។ មិនដឹងឈ្មោះអីគាត់មិនចាំដែរ ។

ណារឿនៈ គេហៅតាអី?

យនៈ ទេមិនចាំទេ ។ ដឹងតែថាប៉ុយឹម បងប៉ុពិនហ្នឹង យ៉ាងម៉េចម៉ែនមិនមែនមិនដឹងទេ ព្រោះឥឡូវវាយូរហើយ ប៉ុគាត់អត់នៅផង ។ ខ្ញុំកើតដឹងក្ដីឡើងប្ដីអត់មានផង អត់មានប្ដីឯណាជីដូនខ្ញុំអីគាត់មេម៉ាយទាំងអស់សុទ្ធតែប្ដីចិនទាំងអស់គ្នាហ្នឹង ។

ណារឿនៈ អ៊ុំដល់ពេលឆ្នាំ ៧៥ ពេលខ្មែរក្រហមវាយបែកភ្នំពេញគេជម្លាសប្រជាជនថ្មីមកគេជម្លាសគ្រួសារអ៊ុំទៅណាដែរ?

យនៈ ស្រេចតែយើងចេញទៅណាចេញទៅ ឲ្យតែចេញផុតពីផ្ទះ ។

ណារឿនៈ គេប្រកាស់ឲ្យចេញតែម្ដង?

យនៈ ចា៎! គេថា៣ថ្ងៃទេចូលវិញ

ខ្ញុំដស្ងូមយកអីវ៉ាន់អ្វាស៎វាថាមិនបាច់ទេម៉ែអើយទុកនៅហ្នឹង

ហើយកូនសោរខ្ញុំឲ្យកូនសោរទាំងអស់ ។ ឲ្យកូនសោគេទុកទៅ គេថាម៉ែឯងបីថ្ងៃទេមកវិញកូនទុកឲ្យបើបាត់អីបន្តិច...

ណារឿនៈ គេហៅម៉ែៗអញ្ចឹង?

យនៈ ហៅម៉ែកូន ម៉ែពុក ។

ណារឿនៈ ទាហានខ្មែរក្រហមគេហៅអញ្ចឹង?

យនៈ ចា៎! មកដល់គេហៅម៉ែអញ្ចឹង មកដល់ជិតស្និតមកតែម្ដង ទាល់តែឃើញងាប់វាយងាប់តាមផ្លូវតើបាននាំគ្នាភ័យ ។

ណារឿនៈ គេប្រាប់ថាម៉េចដិបូង?

យនៈ គេថាឲ្យម៉ែឯងចេញមួយរយៈគេធ្វើការ គេបោសសំអាតសិន ។

ណារឿនៈ បោសសំអាតអីគេដែរ?

យន: មិនដឹងអី គេថាម៉ែឯងមិនបាច់យកអីទៅទេ តែបីថ្ងៃនោះយកបន្តិចបន្តួចបានហើយ វេចទៅ មិនបាច់ដឹកមិនបាច់អីទេ សុំយកម៉ាស៊ីនដេរអីគេថាមិនបាច់ទេម៉ែតែបីថ្ងៃ កូនសន្យាតែបីថ្ងៃបើបាត់អីវ៉ាន់ម៉ែឯងតែបន្តិចកូនសម្ងាប់ឲ្យម៉ែឯងមើល ។ អ្នកកាន់កូនសោរហ្នឹង ។

ណារឿន: គេនិយាយថាអញ្ចឹង?

យន: ចា៎! បើបាត់របស់ម៉ែឯងតែបន្តិច ឲ្យតែម៉ែឯងប្រាប់ថាបាត់ ។

ណារឿន: អ៊ុំជឿគេដែរអត់កាលហ្នុងដល់ព្រូអញ្ចឹង?

យន: ជឿ! ជឿទាំងស្រុងកាលហ្នុងអត់មានគិតអីសោះជឿគេណាស់ បានជាកើតរោគវេទនាហ្នឹងណា ។ សួរដែរតើបើឃើញសាប់ពេញណាពេញណីទៅសួរគេ ហ៊ាននិយាយផ្តេសផ្តាស់សាប់អ្វាស៎ យប់ឡើងឃើញតែវ៉ៃសំរាគខោនៅហ្នឹងម៉ោង១២យប់មិនបាន ឃើញផងដេញឯងចុះទូកទាំងយប់ម៉ោង១២យប់អ្វាស៎ ខ្ញុំចុះទៅក្រោមទៀតណក ។

ណារឿន: ពេលចេញទៅអញ្ចឹងគេអត់មានប្រាប់យើងថាយើងទៅស្រុកនេះស្រុកនោះ ឲ្យយើងចេញសេរីតែម្តង?

យន: អត់ទេ សេរី យើងស្គាល់កន្លែងណាយើងចង់ទៅ ទៅ ៗ ។

ណារឿន: គេមានប្រាប់ថាឥឡូវមានបងប្អូននៅភូមិឃុំណានៅជនបទទៅ?

យន: ចា៎!

ណារឿន: គេប្រាប់អញ្ចឹងអ្ហែស?

យន: ចា៎!

ណារឿន: ដល់ពេលចេញទៅអញ្ចឹងមានទាហានអីនៅតាមផ្លូវប្រាប់យើងថាឲ្យទៅនេះនោះអីទេអ្ហែស?

យន: អត់ទេ បាត់ដឹបងអត់អញ្ចឹងទេ ។

ណារឿន: អត់ទេ ។

យន: ចេញទៅ ដើរអាណាទូលអូសម៉េចទៅ ៗ ទៅតាមរៀងខ្លួនឲ្យតែចិត្តចង់ ហើយពួកខ្ញុំបែក គ្នា១២គ្រួសារហ្នឹងទៅ និយាយគ្នាថាទៅបីថ្ងៃយើងមកជុំគ្នាវិញ ។ ១២គ្រួសារខ្ញុំ ចេញទៅ ១២គ្រួសារណា ។

ណារឿន: ចេញទាំងអស់គ្នាតែម្តង?

យន: ចាំ! អាណាគេទៅភ្នំសំពៅមួយឡែកទៅ អាណាគេទៅភ្នំបាណន់ទៅ ៗ ឲ្យតែមានស្គាល់ អ្នកណាទៅណា ។ ខ្ញុំនឹកឃើញថាចុះទៅតាមមាត់ស្ទឹងទៅមានត្រីញាំ ។ តាមមាត់ស្ទឹង រហូត មែនមានត្រីមែនតើ តានេះហើយឈ្នួលខ្ញុំទៅជាប់អត់ចេញទេ ទៅមកបំរើខ្ញុំ រហូតទាល់ទើបតែមានប្តីទេ រហូតម្តាយមកយកទៅក៏អត់ទៅដែរនៅជាមួយខ្ញុំរហូត ។

ណារឿន: ដល់ពេលចេញទៅ អ៊ុំ ទៅតាមមាត់ស្ទឹងរហូតទៅដល់ស្រុកណា?

យន: ទៅដល់វត្តឯកភ្នំសី ។

ណារឿន: វត្តឯកភ្នំស៊ី ។

យន: គេហៅ ព្រែកនរិន តែខ្ញុំនៅ កៀនវត្តហ្នឹង ។

ណារឿន: ហេតុអីបានអ៊ុំឈប់នៅវត្តឯកភ្នំសស៊ីហ្នឹងអត់បន្តទៅ ទៀត?

យន:

មានគេស្គាល់គ្នានៅហ្នឹងពីសង្គមមកមានអ្នកជិតផ្ទះហ្នឹងគេមានប្រពន្ធគេនៅ ខាង ហ្នឹងណា បានថានៅស្រុកគេហ្នឹងពីបីថ្ងៃសិនទៅ យើងអាលមកចូលផ្ទះយើងវិញ ។ កាលនៅ ត្រឹមចិនដាំស្ពៃទេ ដល់ម៉ោង១២យប់កំពុងតែគេង អាមិត្តផ្ទាំង ហ្នឹងទៅ បាញ់កាំភ្លើង ពេញតែហ្នឹងដេញទាំងយប់ទៀត ម៉ោង១២ អាកូនង៉ាដង ។

ណារឿន: ផ្ទាំង ហ្នឹងពីណាគេ?

យន: គណៈឃុំ គណៈស្រុកគេ អាស៊ី ថ្មើមហ្នឹង ។

ណារឿនៈ ឈ្មោះពេញឈ្មោះអីគេ?

យ៉នៈ ឈ្មោះគេហៅអញ្ចឹងជីងអី នែ៎! សព្វថ្ងៃនៅទេពួកដែលនៅខ្ញុំនៅពីអាពតនៅទេ គណៈភូមិអីនៅ នៅបង់ត្រីអីសព្វថ្ងៃនៅព្រែកនរិនណក តែគេអត់ធ្វើបាប ។ នែ៎ ! មិត្តធឿនអីនៅទាំងអស់ អត់ងាប់ទេ តែពួកខ្ញុំអីចេះតែបិទបាំងឲ្យរស់ទៅព្រោះគាត់ធ្វើ ល្អ គាត់ជួយយើងអ្នាស៎ ។ ទៅសហករណ៍អញ្ចឹង ឲ្យធ្វើត្រីអីអញ្ចឹង ខ្ញុំយប់ឡើងគេឲ្យទៅធ្វើត្រីពាក់អាវប្តីអញ្ចឹងគៅ លួចត្រីគេដាក់ក្នុងអាវ យប់អ្នាស៎ ។ បានត្រីមកយប់ហ្នឹងលាងទាំងយប់ហ្នឹងធ្វើឲ្យម្តាយហ្នឹងម្តាយចាស់អ្នាស៎ ខែធ្វើពោតលួចពោតបានរស់អ្នាស៎ មិនងាយទេ ។

ណារឿនៈ ទៅសំណាក់នៅកន្លែងវត្តឯករង្សីហ្នឹង ព្រែកនរិនហ្នឹង...

យ៉នៈ ដោយសាអ្នកជិតខាងគេបានប្រពន្ធទៅ នៅហ្នឹង នឹកឃើញថាទៅស្គាល់គេទៅ នៅហ្នឹង ទៅ ។

ណារឿនៈ អ្នកជិតខាងហ្នឹងគេទៅជាមួយអ៊ុំដែរ?

យ៉នៈ ទៅ ១២ គ្រួសារ តែ១២គ្រួសារហ្នឹងងាប់អស់ច្រើន ។

ណារឿនៈ អ៊ុំចាំដែរទេពីណាគេខ្លះកាលហ្នុងចេញទៅ?

យ៉នៈ ងាប់អស់ហើយហ្នឹង ។

ណារឿនៈ អញ្ចឹងចេញ១២គ្រួសារមកដល់ឥឡូវមានគ្រួសារណានៅរស់ដែរអត់ ។

យ៉នៈ នៅមានខ្លះ តែនៅកូន ម្តាយឪពុកអីងាប់អស់ហើយ ។

ណារឿនៈ គ្រួសារដែលទៅខាងព្រែកនរិនជាមួយអ៊ុំហ្នឹងមានប៉ុន្មានគ្រួសារដែរ?

យ៉នៈ នៅសល់តែក្មេងៗហ្នឹងវាអត់មានទេចាស់ៗសុទ្ធតែ៧០ ថ្នាយហ្នឹងទៅអស់ហើយ ។

ណារឿនៈ មានប៉ុន្មានគ្រួសារដែរ?

យ៉នៈ ១២គ្រួសារ ដែលយើងចេញពីផ្សារហ្នឹងទៅជិតៗគ្នា១២គ្រួសារហ្នឹង នាំគ្នានិយាយគ្នាថាយើងទៅនៅជុំគ្នា ។

ណារឿនៈ ទៅ នៅ ព្រែកនរិនហ្នឹង?

យនៈ ចា៎!

ណារឿនៈ ចុះអ្នកទៅ នៅភ្នំសំពៅ អីផ្សេងទៀតនោះ?

យនៈ ហ្នឹងអ្នកដែលនៅជិត អ្នកដែលគេស្គាល់បងប្អូនគេផ្សេង ។

ណារឿនៈ ១២គ្រួសារហ្នឹងទៅ នៅ ព្រែកនរិនទៅ ? .

យនៈ អត់ទេណាត់គ្នាទៅ នៅ ចិនដាំស្ពៃ ទៅដល់ចិនដាំស្ពៃអាម៉ោង១២យប់ហ្នឹង មិត្តផ្លាង ហ្នឹងគេបាញ់កាំភ្លើងឲ្យចេញ ។

ណារឿនៈ គេប្រាប់ថាម៉េច ផ្លាងហ្នឹង?

យនៈ គេថាអត់ឲ្យទៅ ទៀត ឲ្យចុះទៅ ទៀត យើងចេះតែចុះហើយ ។

ណារឿនៈ ផ្លាងហ្នឹងឋានៈអីដែរកាលហ្នុង?

យនៈ គេថាគណៈស្រុក គណៈឃុំហ្នឹង ។

ណារឿនៈ គណៈឃុំ ។

យនៈ ឃុំចិនដាំស្ពៃហ្នឹង ។

ណារឿនៈ ឃុំចិនដាំស្ពៃ?

យនៈ ចា៎! តំបន់បួន ។

ណារឿនៈ ពីណាគេគណៈតំបន់បួនអ៊ីកាលហ្នុង?

យនៈ មិនដឹង ។ ដឹងថាតាអេន តាសាន តាជួបីអង្គភាពហ្នឹង អានេះគេហៅ គ្រៅ ទេមិនមែន ទេ...

ណារឿនៈ ផ្លាងហ្នឹងគាត់បាញ់កាំភ្លើងគាត់ប្រាប់ថាឲ្យទៅមុខទៀត?

យនៈ ឲ្យចុះៗ អត់ឲ្យនៅ ទេកន្លែងហ្នឹង ។

ណារឿនៈ ទាំង១២គ្រួសារហ្នឹង?

យនៈ ចា៎! ទៅ ១២គ្រួសារហ្នឹងអត់ឲ្យនៅ ។

ណារឿនៈ ទៅ នៅកន្លែងព្រែកនរិនហ្នឹងបានប៉ុន្មានថ្ងៃ?

យ៉នៈ នៅរហូតដល់៧៨ បានជម្លាសទៅគោកឃ្មុំទៀត ។

ណារឿនៈ ៧៨?

យ៉នៈ ចាំ! ៧៨ចុងបង្ហើយហ្នឹង ។ វាអស់ស្រូវនោះ មួយយប់ៗគេដឹកស្រូវចេញអស់ហើយ គេថាយើងធ្វើស្រែអត់បាន ស៊ីបបរ គេថាអត់ទេឥឡូវចេញពីកន្លែងហ្នឹង ។

ណារឿនៈ ចុះពេលនៅព្រែកនរិនហ្នឹងគេឲ្យធ្វើអីដែរ?

យ៉នៈ ធ្វើស្រែហ្នឹង ។

ណារឿនៈ ទៅដល់ដំបូងអ្នាស់?

យ៉នៈ យាមផ្លូវខ្ញុំកូនខ្ចីគេឲ្យយាមផ្លូវគេចេញទៅឃ្លួននោហ មើលសំបុត្រគេសួរថាយើងចេះអក្សរដែរទេខ្ញុំថាចេះ មើលសំបុត្រ ។

ណារឿនៈ យាមផ្លូវនៅកន្លែងណាអ៊ុំ?

យ៉នៈ យាមនៅអាមាត់ព្រែកក្រូចអ្នាស់ ។ ព្រែកក្រូចហើយបានដល់ព្រែកនរិនយើងមិននៅអាចុងផ្លូវនោះណា មើលឃ្លួនមើលអីអាណាចេញចូលអីទៅណាមកណាអី ។

ណារឿនៈ តាមទឹកហ្នឹងអ្ហែស?

យ៉នៈ នៅលើមាត់ជ្រាំងហ្នឹងនៅលើថ្នល់ហ្នឹង មាត់ស្ទឹងសង្កែហ្នឹង ។

ណារឿនៈ គេឲ្យមើលមនុស្សចេញចូលតាមហ្នឹង?

យ៉នៈ ចាំ! មានសំបុត្រមានស្នាមចេញចូលទៅរកអីណា ។

ណារឿនៈ ចេញចូលមកព្រែកនរិនហ្នឹងអ្ហែស?

យ៉នៈ ចាំ!

ណារឿនៈ អ៊ុំថាគេឲ្យរកឃ្លួនអីម៉េច?

យ៉នៈ ទេ ដល់ក្រោយមិនឃ្លួនចេញពីផ្សារទៅអ្នកដែលសុំទៅស្រុកឃ្លួនវិញនោះ ។ តាមទូកហ្នឹងរស់អ្នាស់ អាលើកទីពីរទីបីអណ្តែតពេញស្ទឹង ។

ណារឿនៈ សុទ្ធតែយួនតែម្តង?

យនៈ ចិនក៏ប្រឡុំធ្វើយួនដែរ ព្រោះចង់ទៅស្រុកគេឲ្យទៅស្រុកនោះ គ្នាប្រឡុំនឹងគេដែរហ្នឹង បងថ្លៃខ្ញុំទៅនឹងគេដែរហ្នឹងទៅមួយអស់ទៅជាប់នៅអ្នកលឿងណាកបាញ់ចោលទាំងអស់ ហ្នឹងបងគាត់បង្កើតណា ដោះអស់ហើយខ្សែដៃអីសកគេថាយួនដែរ ។

ណារឿនៈ អញ្ចឹងយួនដែលចេញទៅតាមទូកទៅតាមស្ទឹងសង្កែទៅហ្នឹង ។

យនៈ លើកទីមួយរួចទៅដល់ ។ លើកទីមួយទីពីរទៅដល់ ដល់ស្រុកមែន ទីបីបានអណ្តែតពេញស្ទឹង ។

ណារឿនៈ ហេតុអីបានលើកទីមួយទីពីរទៅដល់ ទីបីអត់?

យនៈ គេធ្វើអានេះមិនដឹងយ៉ាងម៉េចស្រាប់តែអាវគ្គក្រោយឃើញ ឃើងមិនឃើញគេអញ្ចឹងយើងមិនសកគេថាយើងយួនដែរ វាបានទៅស្រុកគេដែរហ្នឹងណា ទៅអណ្តែតពេញស្ទឹង ។

ណារឿនៈ អញ្ចឹងមានតែគេសម្លាប់ពីលើមក?

យនៈ អាហ្នឹងគេសម្លាប់ពីលើមកហើយតែ អាហ្នឹងខ្ញុំមិនបានឃើញទេណា តែពួកភូមិថាអ្នកដែលទៅយួនអណ្តែតអស់ហើយ ។

ណារឿនៈ មានច្រើនដែរទេអ៊ុំអ្នកដែលទៅ?

យនៈ ច្រើនថាមាសសុខចិត្តអស់ពីខ្លួនឲ្យតែបានទៅនឹងគេ ។

ណារឿនៈ អញ្ចឹងកាលអ៊ុំនាំគ្នារត់ទៅយួនហ្នឹងដឹងថានៅនេះពិបាកខ្លាំងអ្វែស?

យនៈ ចុះបើមកមើលឃើញផាប់នោះ មើលឃើញវាភ្នែកស្រស់ពេក ។ យប់អ្ហាស់គេងអញ្ចឹងមេដប់ខ្ទង់យើងពីដើមចេញទៅមានឈ្មោះមេដប់ខ្ទង់ មេហាសិបខ្ទង់អី គ្នាកំពុងតែដេកជាមួយប្រពន្ធគ្នាកូនគ្នា ប្អូនប្រាំនាក់អីឡើងទៅស្ទូររកគ្នា គ្នាលោតហក់មកពីលើផ្ទះមក ។

ណារឿនៈ ស្គាល់ទេមេដប់ខ្ទង់ពីណាគេ?

យនៈ ទេមេដប់ខ្ទង់ព្រែកនិនហ្នឹង ប្តីមីថាន ហ្នឹងមិនដឹងជាឈ្មោះអី លោតចុះពីលើផ្ទះ ។

ណារឿនៈ ម៉េចបានលោត?

យនៈ គេថាយើងមេដប់ខ្នង គេយកទៅសម្លាប់ ឲ្យតែយប់ទៅហើយ ។

ណារឿនៈ មេដប់ខ្នងសម័យ លន់ នល់ អ្ហែស?

យនៈ ចាំ! ឲ្យតែដឹង ។

ណារឿនៈ អញ្ចឹងដោយសារអញ្ចឹងប្រជាជនភ័យ ពុគេថាឲ្យទៅស្រុកយួនពីណាគេជនជាតិយួនឲ្យត្រឡប់ទៅស្រុកវិញអញ្ចឹង ខ្មែរយើងខ្វះប្រឡុំទៅដែរ?

យនៈ បន្ទុំដែរ បងថ្លៃខ្ញុំហ្នឹងទៅដែរហ្នឹង ។

ណារឿនៈ ឈ្មោះអីដែរ?

យនៈ ឈ្មោះ ហាង តុង ។

ណារឿនៈ គាត់ទៅមួយគ្រួសារអ្ហែស?

យនៈ បងគាត់បង្កើត គាត់ទៅមួយគ្រួសារ ។

ណារឿនៈ ទៅហ្នឹងទៅពេលលើកទីបី ឬលើកទីមួយ?

យនៈ លើកទីបី ខ្ញុំអួសដៃឡើងហើយណា ខ្ញុំហៅចេញពីទូកមកខ្ញុំនៅយាមហ្នុងណាខ្ញុំថាលើកទីមួយដល់លើកទីពីរដល់ លើកទីបីអញខ្លាចអណ្តែតពេញទឹកណា ។ វាសោឯងចេះតែនិយាយហើយ និយាយធ្វើអីមិនទេបានទៅ ហើយខ្ញុំឲ្យមាសគេអស់ហើយ ។

ណារឿនៈ ចុះក្រោយមកពុដំណឹងថាម៉េចទៅ?

យនៈ ទៅគេបាញ់ងាប់អស់ទៅ ។

ណារឿនៈ អ៊ុំដឹងពីណាមកថាគេបាញ់ងាប់?

យនៈ តែពួកហ្នឹងខ្សែអាអ្នកដែលគេដឹងហ្នឹងយើងចេះតែពុជាមួយគេទៅណា តែការពិតឥឡូវ យើងស៊ើទៅវាបាត់មែន ។

ណារឿនៈ មកដល់ឥឡូវមានបានពុដំណឹងពីគាត់ដែរទេអ៊ុំ?

យនៈ ងាប់អស់ហើយដឹងងាប់ហើយទេ ថាងាប់នៅអ្នកលឿងថាគេបាញ់ចោល ។

ណារឿនៈ អាហ្នឹងនៅឆ្នាំណាដែរ ៧៥ឬ៧៦?

យនៈ មិនមែន៧៥ទេ ចូល៧៦ហើយ អាណាចង់ទៅឲ្យទៅណា ។

ណារឿនៈ អញ្ចឹងមួយគ្រួសារគាត់ហ្នឹងទៅទាំងអស់នៅតែមួយ?

យនៈ ទៅទាំងអស់នៅតែមួយ

នៅធ្វើការជាមួយពួកខ្មែរក្រហមផ្តាច់ខ្លួនទៅចូលយួនណក ។

ណារឿនៈ ឆ្នាំចិតប៉ុន្មានពេលហ្នុង?

យនៈ ចុង៧៥ហើយ ។

ណារឿនៈ ពេលហ្នឹងមានខ្មែរក្រហមផ្តាច់ខ្លួនចូលយួនដែរ?

យនៈ ........អត់ទាន់ចូល៧៦ទៅ ជិតចូល៧៦ហើយ ។

ណារឿនៈ កូនស្រីគាត់ទៅតាមដែរអ្ហែស?

យនៈ គេអត់ឲ្យចូល គេថាចូលអីម៉ែឪឯងគេដឹកយកទៅវ៉ៃចោលអស់ហើយ ។

ណារឿនៈ ខាងខ្មែរក្រហមគេប្រាប់ថាអញ្ចឹងដែរ?

យនៈ ទេ អ្នកក្នុងភូមិអ្ហាស៎ ទៅដល់អ្នកលឿងហ្នឹងហើយ វាអញ្ចែកកាលហ្នុងក្មេងៗនៅចល័តអ្ហាស៎ ធ្វើការមកវិញទៅ គេប្រាប់រស់បានដល់សព្វថ្ងៃហ្នឹងទៅ ។

ណារឿនៈ ចុះអ៊ុំនៅយាមផ្លូវហ្នឹងរហូត?

យនៈ អត់ទេ ទៅច្រូតដូចខ្ញុំថាមួយថ្ងៃ ១៥ កណ្តាប់ ខ្ញុំធ្វើអត់បានហ្នឹង ។ ចុះអាលែងទៅចាប់អាចុងស្រូវឯណោះ ទំរាំតែយកកណ្តៀវទៅច្រូតទៀតនោះ ។

ណារឿនៈ អ៊ុំអ្នកស្រុកផ្សារ ។

យនៈ ចា៎! ខ្ញុំផ្ទៃផ្កានៅផ្សារទាំងអស់ ខ្ញុំកើតមកផ្សារសុទ្ធ កុំតែបានប្តីតើ ដល់មកទៅវេទនាពេក ។

ណារឿនៈ ប្តីអ៊ុំកាលហ្នុងធ្វើអីដែរ?

យនៈ អត់ទាងកាប់អូស ហើយមកដាំបាយ បានតែប្រាំថ្ងៃដកចេញទៅដាំស្តែ ។ នឹកឃើញថាទៅរើផ្ទះមករើផ្ទះ ។

ណារឿនៈ អ៊ុំថាពេលមករើផ្ទះហ្នឹងឆ្នាំណាដែរ?

យនៈ ចុងឆ្នាំ៧៥ ។

ណារឿនៈ ដើម៧៦អ្ហែស?

យនៈ ផ្ទះខញ្ញាដុចអីនេះរើអស់តើយកទៅក្រោមអស់ ។

ណារឿនៈ ថាទៅជួបម៉ាពេញហ្នឹង?

យនៈ ចា៎! ម៉ាពេញហ្នឹងហើយដែលបានរើផ្ទះហ្នឹង ។

ណារឿនៈ គាត់ទៅម្នាក់គាត់ឬមានគ្នាដែរកាលហ្នុង?

យនៈ អត់ទេ អាទៅមានគ្នាចាំមើលមកសួរមើល លបៗទៅតែឯង ។

ណារឿនៈ គេឲ្យគាត់ទៅរើផ្ទះតើអ្ហីកាលហ្នុង?

យនៈ ឲ្យរើផ្ទះហើយដាក់ជាក្បូនទៅបណ្តែតទឹកទៅវិញណា ។

ណារឿនៈ

អញ្ចឹងមានន័យថាគាត់ទៅរើផ្ទះកន្ទែងហ្នឹងគាត់ឈ្មៀតឲ្យកាសហ្នឹងទៅជួបម៉ាពាញហ្នឹង ផង ។

យនៈ ម៉ែគាត់ចេះតែយំពេក

ទៅសុំគ្នាឯងដែលទៅរើជាមួយហ្នឹងសុំគ្នាឯងទៅថាឲ្យខ្ញុំទៅជួប

សុំឲ្យខ្ញុំទៅជួបសុំឲ្យម៉ែខ្ញុំអញ្ចឹងណា៎ ។

ណារឿនៈ អញ្ចឹងដល់ពេលទៅជួបម៉ាពាញហ្នឹងក៏អត់អាចជួយបានដែរ?

យនៈ គាត់អត់ដឹងអី គាត់ថាគាត់អត់ដឹងអីទេស្រេចនឹងគេណា ។

ណារឿនៈ ចុះអ៊ុំកាលហ្នឹងម៉េចមិនសុំទៅជួប នួន ជា តែម្តង?

យនៈ សុំម៉េចកើតយើងមានអីទៅសុំគេ មិនហ៊ាននិយាយឈ្មោះគេផងហ្នឹងណា អត់ទេអត់ហ៊ានថាមានអ្នកធំអីអញ្ចឹងផងអត់ហ៊ានទេ អត់ហ៊ានសោះស្រងំឈឹងខ្ញុំខ្លាចលេខមួយ ។

ណារឿនៈ ចុះអ៊ុំកាលនៅផ្សារអីអញ្ចឹងអត់ដែលជួប តានួន ជា អីទេអ្ហែស?

យ៉ន៖ អត់ដែលទេ គាត់នៅ ធ្វើកម្មករកប៉ាល់នោះ នួន ជា ដំបូងនៅ ធ្វើកម្មករកប៉ាល់ទេ អត់ទាន់បានចូលស៊ុបទេណា គាត់នៅ ម្តាយគ្រាន់តែដឹងថាកូននៅ ធ្វើកម្មករហ្នឹងគាត់ទៅ ម្តាយទៅស្គាល់ផ្ទះស្អែកឡើងរើហើយ អត់ឲ្យជួប ។

ណារឿន៖ គានួន ជា ហ្នឹង?

យ៉ន៖ ចាំ! អត់ឲ្យជួបទេ អត់ចូលផ្ទះ៥០ឆ្នាំហើយ គាត់ខឹងគាត់ថាគយចាប់អីវ៉ាន់គាត់ហ្នឹង ចាប់អាគេរត់ពន្ធមិនចាប់មកចាប់របស់គាត់បានជាគាត់ចូលខ្មែរក្រហម គាត់និយាយតើ គាត់បកស្រាយតើ ។

ណារឿន៖ គយ លន់ នល់ ឬគយសី ហនុ?

យ៉ន៖ គយ សី ហនុ ។ គាត់ជាប់បាក់ឌុបជិនាន់នោះហើយគាត់ពាក់តែមួកកន្តឹកលីអីវ៉ាន់ឡើង កប៉ាល់ធ្វើតែកម្មកររហូតហ្នឹង ។ ឆាប់ហើយគាត់វេទនាណាស់គាត់ហែលអស់ចិត្តគាត់ គាត់ធ្វើគ្រូណាំ ។

ណារឿន៖ អ៊ុំថាគាត់ធ្វើកម្មករកប៉ាល់អាហ្នឹងតាំងពីសម័យសម្តេច សី ហនុ អ្ហែស?

យ៉ន៖ ចាំ!

ណារឿន៖ គាត់ជាប់បាក់ឌុបហើយនៅ?

យ៉ន៖ ជាប់ហើយ លបៗទៅជួប ម្តាយលបទៅជួបដឹងដំណឹងថាកូននៅទីនោះ ស្អែកឡើង មិនបាច់ដើររកទេគេថារើផ្ទះបាត់ហើយ ។

ណារឿន៖ ម៉េចអញ្ចឹង?

យ៉ន៖ អត់ឲ្យជួប អត់ឲ្យម្តាយជួបទេ តែហ៊ាស្គាល់កន្លែងហើយស្អែកឡើងមិនបាច់ទៅជួប ទៀតទេ បាត់ហើយជញ្ជូនចេញបាត់ ។

ណារឿន៖ អញ្ចឹងគាត់អត់ដែលមកលេងម្តាយរបស់គាត់ទេ?

យ៉ន៖ អត់ទេ ៥០ ឆ្នាំបាត់ ៥០ ឆ្នាំ ។

ណារឿនៈ អ៊ុំអត់ដែលបានជួបមុខគាត់ដែរអញ្ចឹង?

យនៈ អត់ទេ ខ្ញុំមិនដែលឃើញផង មិនដែលស្គាល់ផង តែឥឡូវកូនខ្ញុំវាស្គាល់ ខ្ញុំមិនស្គាល់ កូនខ្ញុំស្គាល់អាធំធ្វើប៉ូលីសស្គាល់ខ្ញុំអត់ស្គាល់ទេ ។

ណារឿនៈ អញ្ចឹងអ៊ុំដល់ពេលតាគាត់ទៅជួបម្ដងអញ្ចឹងម្ដាស់ មិនមែនអញ្ចឹងទៅសុំពីរដងហើយ តារ៉ុម្ដង ។

យនៈ ផ្ដាំតាមតារ៉ុម្ដង មានឱកាសលួចទៅបាន អាប្អូនខ្ញុំមួយទៀត ។

ណារឿនៈ អញ្ចឹងទៅបីសារអញ្ចឹង?

យនៈ ទៅពីរសាទាំងផ្ដាំបីសា ។

ណារឿនៈ នេះតាន្ធូន ជា ។

យនៈ ខ្ញុំអត់ស្គាល់ទេទាល់តែអាកូនខ្ញុំបានស្គាល់ អាធ្វើប៉ូលីសហ្នឹងទៅជួប ។ ទៅជួបហៅតា ដែរ ថាម៉េចបានមិនទៅលេងអីអញ្ចឹងណា ថាម៉ែអត់ទៅទេ ខ្ញុំខឹងខ្ញុំរហូតខ្ញុំខឹងបាត់បង់ ប្រុសខ្ញុំ ខ្ញុំមិនដែលនិយាយឈ្មោះផងហ្នឹង ។

ណារឿនៈ អ៊ុំថាប្អូនប្រុសម្នាក់ទៀតទៅជួបដែរ?

យនៈ ទៅជួបអាហ្នឹងសព្វថ្ងៃនៅធ្វើដុកទ័រនៅស្ដៅ ដុកទ័រ ។

ណារឿនៈ ហេតុអីបានជាគាត់ទៅជួបម្ដងទៀត?

យនៈ ទៅដោយសាររឿងម៉ែខ្ញុំហ្នឹងណាថាឲ្យអង្វរកថាឲ្យជួយបងប្រុសខ្ញុំផង ម៉ែខ្ញុំគាត់យំ គាត់ថាឲ្យគាត់ស្លាប់ក៏ឲ្យសុំឃើញមុខកូន គេថាអត់ ។

ណារឿនៈ ទៅមួយសាទៀតទៅជួបពីណាគេ ទៅជួបយាយពាញដែរអ្ហែស?

យនៈ ទៅតែម៉ាពាញហ្នឹង គេមិនដែលបានជួបគេទេ ។

**ចប់កាសែតទីមួយ**

យនៈ ធូរណាស់អញមិនមែនអ្នកសាងប្រទេសជាតិឯណា នឹងអាកាត់បានកូន ង៉ែញមិនដឹងទេ ពីដើមអញដើរយំរហាមដើររកវា វាមិនឲ្យយើងជួបផង ។

ណារឿនៈ គាត់ថាអញ្ចឹង?

យនៈ ចាំ! ង៉ែញអញយំយូរណាស់ហើយង៉ែញមិនឃើញទេ ង៉ែញឃើញអញយំរហូតទេ តាមរកវា ទៅជួបវាបានតែមួយថ្ងៃស្អែកឡើងមិនបាត់យកស្ករទៅឲ្យវាស៊ីទៀតទេ គ្នាដក់អីៗយកទៅ អាម្ហូបឆ្ងាញ់ៗទៅឲ្យស៊ីនៅអាផែកប៉ាល់ហ្នឹង ក្រោយបាត់ឈប់ធ្វើ ហើយទៅធ្វើឯណាផ្សេងមិនឲ្យស្គាល់ទេ ។

ណារឿនៈ ផែកប៉ាល់ហ្នឹងនៅម្តុំណាដែរ គាត់ធ្វើផែកប៉ាល់ហ្នឹង?

យនៈ មិនដឹងទេ ព្រុថាផែកប៉ាល់ខ្ញុំក៏មិនដឹងដែរ លីសែង មិនមែនធ្វើមេគេទេណាលីសែងនឹង ស្មាណា ។

ណារឿនៈ គាត់ជាប់បាក់ឌុបដែរអ្ហែស?

យនៈ ជាប់បាក់ឌុបតែអត់ធ្វើការណា គេចេញចល័តស៊ើបណាតាមមើលអ្ហាស់ អានេះបែប រនុកកក្នុងអីណា ។

ណារឿនៈ ធ្វើរនុកក្នុងអីអញ្ចឹង?

យនៈ ចាំ! ពាក់មួកមិនដែលឃើញមុខទេណា សិតតែដាក់កន្ទីបអញ្ចឹង ទៅដល់មើលកូនឯង មិនស្គាល់ទេ ទាល់តែបើកមួកវាណាក ។ ទាញបិទមុខជិត ។

ណារឿនៈ អាយុគាត់ប្រហែលជាប៉ុន្មានដែរ?

យនៈ មិនដឹងជាប៉ុន្មានឥឡូវគាត់...

ណារឿនៈ ឥឡូវ៨០ជាងហើយ ។

យនៈ អាកូនខ្ញុំថាម៉ែអើយចាស់ណាស់ចាស់មែនទែន ។

ណារឿនៈ អញ្ចឹងកូនរបស់អ៊ុំធ្លាប់ទៅជួបគាត់ដែរ?

យនៈ ទៅ ។

ណារឿនៈ ឆ្នាំណាដែរ?

យនៈ ទៅកាលយើងគេវៃ ជិតវៃសំឡូតហ្នឹង វាទៅធ្វើគេចុះឈ្មោះអីប្រជាជននោះ គេឲ្យទៅ ជំរឿននោះ ។ ចុះម្តុំហ្នឹងសុទ្ធតែខ្មែរក្រហមនោះ ។

ណារឿនៈ ចុះក្រោយមកទៀតដូចថាទៅជួយអត់បានអញ្ចឹង បាត់ដំណឹងគាត់ឈឹងរហូតមក ។

យនៈ ឈឹងអត់មានបានទាក់ទងទៀតទេ ។

ណារឿនៈ អត់មានបានរកវិធីអីទៀតស៊ើបទេអ្អែស?

យនៈ អទ់ទេចប់ដល់ស៊ើប អាពេលយើងចប់ចូលមកនេះណា ស៊ើបចូលមកផង មើលហោរផងមើលរហូតដល់ឥឡូវនៅតែមើលដែរ នៅតែមើលតែគេថាសូន្យៗអញ្ចឹង ។

ណារឿនៈ ហោរគេថាសូន្យដែរ?

យនៈ ចា៎! គេថាសូន្យអត់រស់ទេ ទៅមើលឯណាក៏គេថាស្លាប់ដែរ អារឿងហ្នឹងអារឿងពីជំនាន់ហ្នុងអាណាថាស្លាប់វាស្រណំហើយ ។

ណារឿនៈ ចុះគានិយាយពីគ្រួសារអ៊ុំវិញ ពេលដែលគាត់ទៅរើឈើអីហើយ យាយពាញ គាត់ផ្ញើដូងអីដែរអ្អែស?

យនៈ ផ្ញើអី ឲ្យទៅយកខ្លួនឯងហ្នឹង ប្រកមួយបាវន្នែនមកតែម្តង ឲ្យយកមកឲ្យខ្ញុំអីនោះនៅជាមួយគ្នានោះ ឲ្យខ្ញុំអីហ្នឹងនៅជាមួយគ្នានោះ ម៉ែខ្ញុំអីហ្នឹងហើយ ឪវាដើររកត្រីអីឲ្យទទួលទានហ្នឹង ។ គាត់មើលចៅ ។

ណារឿនៈ បានហូបដែរទេពេលមកដល់ផ្ទះ?

យនៈ ចុះយើងស្ងាត់ៗទៅយប់ តែថាយើងដូចថាមានរបស់អីឲ្យ វារកគ្រឿងក្រអូបរកខោអាវស្អាតអីឲ្យទៅ មេកងណា៎ ។ ហើយថាម៉េចបានជាម៉ែឯងភ្ញើងអីរហូតអញ្ចឹងថាម៉ែ ឃ្លានណាស់កូនអើយអាណិតម៉ែទៅ ម៉ែដាំទឹកក្តៅអីហូបវាឃ្លាននោះ ។ ផ្ទះខ្ញុំយាម រហូតហ្នឹង យប់អ្ហាស៎សុទ្ធតែខ្មៅរហូត ភ្ញាក់ឡើងញ័រសព្វសាច់អស់ បើកភ្នែកឡើងខ្ញុំ កូនប្អូនទទួលទានដំណេកអញ្ចឹង ខ្ញុំឈឺនោមទៅ នោមវាចាប់ដៃខ្ញុំជាប់សួរខ្ញុំថាទៅលាក់អី ។

ណារឿនៈ យប់ឡើងហ្នឹង?

យនៈ ចា៎! ខ្ញុំថាបទដើងតូចម៉េចមិនឆ្លួលមើល ខ្ញុំនោមទេ គ្មានបានដេកទេទាល់ព្រឹក ។

ណារឿនៈ យាមអញ្ចឹងរហូតទាល់តែបែកតែម្តង?

យនៈ ចា៎! ទេបើភ្នែកឡើងឃើញរាល់តែថ្ងៃ ។

ណារឿនៈ គ្នាច្រើនដែរទេ?

យនៈ

ច្រើនឃើញរាល់តែថ្ងៃហើយសុទ្ធតែគាំភ្លើងអាហ្នឹងបើយើងពីរនាក់បីប្រពន្ធអីមកពីកាប់ អុសអីក្លាតមាត់និយាយអីសុទ្ធតែងាប់ហើយ តែខ្ញុំហានិយាយឡើងប្តីបិទមាត់ជិតព្រោះ គេដឹងអត់ឲ្យនិយាយដេកទៅលក់ក៏ដោយមិនលក់ក៏ដោយដេកទៅ ។ យប់ឡើងតាខ្ញុំមិន ឲ្យនិយាយទេបើខ្ញុំងាប់បាត់ហើយមិនរស់ទេ ។ តានេះគេចងយកទៅវៃណា ងាប់ចងយកទៅវៃចោលកុំតែគេសុំមកហ្នឹងកុំអីងាប់បាត់ហើយ ។

ណារឿនៈ ម៉េចបានគេចង?

យនៈ ម៉េចឪវានិយាយមើល ។ គេសួរយើងទៅមើលគោហើយនិងរែកទឹកឲ្យចុងភៅគ្រាន់តែឃុំខុសគ្នាណាឃុំយើងគេឲ្យយើងរែកទឹកតែគោយើងអត់ទាន់បានយកទៅចងទេគេឲ្យរែកទឹក ។ ដល់គេមកដល់គេថានេះគោរបស់អាណាគេហ្នឹង ខ្ញុំថារបស់ខ្ញុំវាថាម៉េចមិនយកទៅចង ខ្ញុំថារែកទឹកឲ្យចុងភៅសិន តែប៉ុនហ្នឹងគេចាប់ខ្ញុំចង ។ ដល់គណៈឃុំខ្ញុំអាអេនហ្នឹងថាប៉ុណ្ណឹងឯងចងគេម៉េចអ្ហាស៎ ឃុំមួយ ឃុំពីរអ្ហាស៎ ។

ណារឿនៈ អញ្ចឹងមនុស្សម្នាក់នៅក្រោមឃុំពីរគ្រប់គ្រងអញ្ចឹង?

យនៈ អត់ទេឃុំខាងនរិនទៅ ខាងព្រែកអញ្ច្រែងហ្នឹងឃុំមួយ ដល់នរិនឃុំមួយទៀត អន្តភាពគេបីអន្តភាព ។

ណារឿនៈ នៅឃុំតែមួយទេ?

យនៈ នៅតំបន់តែមួយតែឃុំខុសគ្នា ។

ណារឿនៈ ចុះម៉េចខាងឃុំនោះមកបញ្ជោរអុំដែរ?

ប្ដីៈ វាទៅជាមួយគ្នាឃុំមួយឃុំពីរទៅជាប់តែវាលស្បូវអញ្ចឹងតើខាងយើងនៅនេះខាងគេនៅខាងលើទៅរែកទឹកតាមផ្លូវហ្នឹង ហើយចុងភៅនៅក្បែរហ្នឹង ។ អាហ្នឹងគេថាត មាត់ ។

ណារឿនៈ គ្រាន់តែសួរយើងឆ្លើយអាហ្នឹងមិនមែនតមាត់ឯណា?

យនៈ ចា៎! ឆ្លើយ តាហ្នឹងគាត់ចិនមិនមែននិយាយច្បាស់ឯណា ថាខ្ញុំរែកទឹកសិន ។

ណារឿនៈ ដល់ពេលអញ្ចឹងយ៉ាងម៉េចទៅ?

យនៈ គណៈឃុំខ្ញុំតាអេនគាត់ថាងាប់ហើយគ្នារែកទឹកឲ្យចុងភៅចងគ្នាយកទៅវ៉ៃចោលយ៉ាងម៉េច ។ គាត់អត់ឲ្យចង ។

ណារឿនៈ ពីណាគេអ្នកចងដំបូង?

យនៈ ឃុំពីរ ឃុំព្រែកកញ្ជ្រែង ។

ណារឿនៈ ឈ្មោះអីគេដែរគណៈឃុំកាលហ្នុង?

យនៈ ឈ្មោះតាថ្វាង ។

ណារឿនៈ តាអេន ប្រាប់តាថ្វាង ហ្នឹងថាឲ្យលែងវិញ?

យនៈ ថាអត់ឲ្យចងទេ វាស្រាយវិញទៅ ។

ណារឿនៈ អញ្ចឹងបានរួចមកវិញមក?

យនៈ ចា៎! បានរស់មកដល់សព្វថ្ងៃហ្នឹង កុំអីទៅបាត់ហើយ ។

ណារឿនៈ អញ្ចឹងតាក្រៅពីធ្វើនៅហ្នុងរែកទឹកមើលគោអីហ្នឹងគេឲ្យធ្វើអីទៀតទៅ?

យនៈ ចល័តគាត់ហ្នឹងដូចថារើឈើ ៗអត់មានប្រកែកទេ ទៅកាប់អុស ៗ ឈប់ទៅតាឯឈប់ កាប់អុសដាំស្ល ៗ ចូលចុងភៅ ៗ ។ ម៉ោង១២យប់វាប្រើក៏ទៅដែរអត់មានដាច់ខាត អានេះស្ងួនណាស់ឯងវ៉ៃវាចោលម៉េច ប្រើវាបានអានេះណា៎ថាអញ្ចឹង ហើយខ្ញុំនៅផ្ទះខ្ញុំឆ្លាត ពេលណាវាចង់បានគ្រឿងក្រអូបអីវាមកខ្សឹប ម៉ែមានរបស់ល្អទេ ។

ណារឿនៈ វាហៅម៉ែអញ្ចឹង?

យនៈ ចា៎! វាហៅម៉ែ ។

ណារឿនៈ ក្មេងៗឬចាស់អុំ?

យនៈ ក្មេង ចាស់ក៏ហៅម៉ែដែរ ស្រីផងប្រុសផង ។ ដល់ទៅវាថាម៉ែឯងធ្វើចុងភៅទៅ តែយកអាវយឺតអាល្អឲ្យខ្ញុំមួយមកណា ម៉ង់គេហ្គុយអីណាម៉ែ របស់បារាំងអ្នាស់ ។

ណារឿនៈ ដឹងម៉ង់គេហ្គុយដែរ?

យនៈ ចុះរបស់របរខ្ញុំស្លៀកមានទៅនេះអី ។

ណារឿនៈ ពេលជម្លាសចេញពីនេះទៅយកទៅតាម?

យនៈ ចា៎! យកអាអាវស្លៀកពាក់ល្អៗយកទៅតាមដែរយើងមិនថានេះទេ យើងរេចទៅ អាចាស់យើងអារបស់យើងមិនត្រូវយកវាហាមមិនឲ្យយកយើងយកតែអាស្រាលៗ ខោអាវយើងស្លៀកពាក់ណា ហើយនឹងខោអាវកូនហ្នឹង បានអាហ្នឹងឯងយកទៅដូរ... វាចង់ល្អលើសយើងទៅទៀត ឆាប់ហើយ!

ណារឿនៈ ចុះកាលហ្នុងគេបែងចែកវណ្ណៈឲ្យស្មើគ្នា?

យនៈ វាស្រឡាញ់ប្រុសលើសយើងទៅទៀត នៅតាមរណ្ដៅអីទៅមើលគ្នាវាណក ឆាប់ហើយ! ខ្ញុំវាថាម៉ែឯងធ្វើចុងភៅទៅ ខ្ញុំធ្វើចុងភៅ វាថាម៉ែនាំគេទៅដាំចេក ដាំអំពៅ ទៅ ដាំអំពៅខ្ញុំអាណិតអ្នកអត់ស៊ី ខ្ញុំដាំតែថ្នាំងៗក៏ចេះតែដុះដែរ ទេវតាជួយលោកអើយដុះល្អណាស់ខ្ញុំឲ្យសាច់ៗគេស៊ីអស់ហើយខ្ញុំទៅប្រាប់វាថាមិត្ត ឯងកុំធ្វើបាបណាក្រុមរបស់ខ្ញុំកងរបស់ខ្ញុំហ្នឹងណាកងហ្នឹងខ្ញុំសុំដូចថាថ្ងៃឡើងវាហេវខ្លាំ ងណាស់សុំចេកអ្នាស់អាខ្នាយជ្រូកអីកុំឲ្យមើលណាខ្ញុំដាក់ផ្លាងក្នុងកណ្ដាលចំការហ្នឹងណា ។ ស្ងោរចែកគ្នា ស៊ីទៅ ។

ណារឿនៈ ខ្នែងជ្រូកម៉េច?

យនៈ អាដែលមិនទាន់ចាស់ហ្នឹងណា៎ ដែលវាមិនទាន់ចាស់អីយើងកាប់យកមកស្ងោរចែកគ្នា ស៊ីគ្រាន់កុំឲ្យវាហេវឃ្លានពេកណា ។

ណារឿនៈ សុំវាអញ្ចឹងគេឲ្យដែរទេ?

យនៈ ទេលាក់ការទេ សុំមេកងពួកម៉ិនិរតីអីហ្នឹងណា ។

ណារឿនៈ ឈ្មោះអីដែរមេកងអុំកាលហ្នុង?

យនៈ ទេមិនដឹងកាលហ្នុងឈ្មោះអីទេ មិននារីៗហ្នឹង ។

ណារឿនៈ គាត់មកពីខាងណាមិត្តនារីអីហ្នឹង?

យនៈ និរតី ហើយយប់ឡើងវាចង់ឆ្ងាញ់ដែរណា វាអត់បេះម្ហូបទទួលទានទេ វាថាម៉ែៗឯងបេះធ្វើអីដែរ ឯងចង់ហូបអី? វាថារបស់ធំៗណាស់ម៉ែអើយទេ ៗផ្ទះខ្ញុំឆ្ងូតទឹកឲ្យស្អាតទៅផ្ទះខ្ញុំ ។ ទៅឆ្នាំលេខធំៗអញ្ចឹងវាមានគ្នាបីនាក់អីខ្ញុំដាំពេញៗតើ ។ ចុះអង្កខ្ទះអីកើបមកដាំពេញៗ ត្រីឆ្អិនស្ងួតតែពងប៉ុន ៗនេះលោកអើយ! ប៊ីចេងខ្ទឹមសយើងធ្វើបានដូចយើងពីសង្គមអញ្ចឹងធ្វើឲ្យវាស៊ីអ្ហាស់

តែវាអត់មានស៊ីដូចយើង ទេ ស៊ីតែបន្តិច ពងវាមិនស៊ីផង វាស៊ីតែសាច់ហើយបាយស៊ីបន្តិចហ្នឹង ។ ខ្ញុំក្រមារ ផ្កាប់វេចមកយប់ឡើងក្នុងមុង ពួយឆ្អែតកូនចៅកេះឡើងឆ្អែតអស់ហើយកូនណា ។

ណារឿនៈ យើងសុំគេមក ឬលួចយកមក?

យនៈ ទេគេឲ្យ សល់វាថាម៉ែឯងយកទៅយកឲ្យកូនចៅម៉ែឯងទៅ តែលាក់ការណា ។

ណារឿនៈ ចុះយកមកអញ្ចឹង យប់ឡើងអុំថាមានគេអ្នកយាមនោះ?

យនៈ យាមតែយប់ពេលយើងគេងទេ ពេលគេងណា ពេលគេងបានយ៉ាប់អត់ធ្វើអីបានទេ ពេលយើងមកហ្នឹង យើងរួចរាល់អស់ហើយ យើងចងមុងអីឲ្យកូនទៅណា ។

ណារឿនៈ អត់ទាន់មានគេមកយាមទេអ្ហែស?

យនៈ នៅទេ ដល់យើងឆ្អែតអស់ហើយ យើងគេង ។ ក្រោកនោមលេងចាប់ខ្ញុំដាប់ខ្ញុំថាឈ្លួលមើលទឹកនោម ឥឡូវខ្ញុំមានអីកប់ទៀត មិត្តអើយមិត្តខ្ញុំមានអីកប់វាថាយើងកប់មាសកប់ប្រាប់ ។ដេកចាំតែថ្ងៃងាប់មែនណា

សព្វថ្ងៃកន្លែងហ្នឹងខ្ញុំអត់ទៅ ដាន់សោះចង់អ្នកណាផ្ដាំម៉េចក៏ខ្ញុំអត់ទៅសោះ លោកអើយលោកកន្លែងខ្ញុំនៅហ្នឹង ។

ណារឿនៈ ហេតុអីបានជាអត់ទៅ ?

យនៈ ទេដូចជាខ្លាចតែម្ដង មានការគេអញ្ជើញការអីលោកកូនខ្ញុំអីប្ដីខ្ញុំអីអញ្ជើញទៅចុះ ខ្ញុំមួយខ្ញុំសុំហើយ អត់ទៅទាល់តែសោះ ។

ណារឿនៈ ដូចថាបាក់ស្បាត ។

យនៈ ចាំ! ខ្លាចភូមិហ្នឹងតែម្ដង ហើយទៅគេដេរយើងថា អាអ្នកភូមិគ្នាឯងហ្នឹងថាមកពីគ្រួសារនាឯងច្រើន ១២ គ្រួសារមកដាន់កកគេ ឥឡូវរកអង្កសុីគ្មាន វាមិនគិតថាអាអង្គការហ្នឹងយ៉ាងម៉េចអត់ ។

ណារឿនៈ អាពេលសម័យខ្មែរក្រហមហ្នឹង?

យនៈ ហ្នឹងហើយវាមិនគិតទេ វាថាអាពួកយើងហ្នឹងទៅដាន់ក៏ធ្វើបាបវា ។

ណារឿនៈ ពួកមូលដ្ឋានហ្នឹងអ្ហែស?

យនៈ ចាំ!

ណារឿនៈ ចុះអុំកាលហ្នុងគេឲ្យហូបអីដែរ?

យនៈ មុនដំបូងបាយតើ ។

ណារឿនៈ មុនដំបូងបាយ ។

យនៈ ដល់ក្រោយមកបបររឹង ។

ណារឿនៈ ហូបបាយបានប៉ុន្មានឆ្នាំ?

យនៈ បាយបានជាងកន្លះឆ្នាំ មកបបរនៅគ្រាន់ណាដល់ក្រោយលេងមែនទែន ដល់ខ្ញុំពេលក្រោយគេឲ្យចិញ្ចឹមជ្រូក ។

ណារឿនៈ អុំដូចថាពេលបាយដំបូងអញ្ចឹងអ្ហាស់ ដល់ក្រោយមកបានបបរ...

យនៈ មុនដំបូងអញ្ចេះ មុនដំបូងចែករបប ចែកស្រូវ ។

ណារឿនៈ តាមផ្ទះអ្វែស?

យនៈ តាមផ្ទះគេឲ្យយើងទៅយកតាមកំលាំង កំលាំងទីមួយកំលាំងទីពីរ កំលាំងទីបី ។

ណារឿនៈ ចុះអ៊ុំកំលាំងទីប៉ុន្មានដែរ?

យនៈ ខ្ញុំកំលាំងទីពីរ ប្ដីទីមួយ ។

ណារឿនៈ កំលាំងទីមួយគេឲ្យប៉ុន្មានដែរស្រូវ?

យនៈ ៦កំប៉ុងមុនដំបូងអ្នាស់គេឲ្យច្រើនអ្នាស់ ។

ណារឿនៈ មិនមែនអត់ទេអ្វែស?

យនៈ ទេ ស្រូវ ហើយដាំខ្លួនឯងប្រាំមួយស្រូវអ្នាស់ ឲ្យស្រូវមិនមែនឲ្យអង្ករទេណា ទីពីរបួនកំប៉ុង ទីបី ពីរកំប៉ុង ។

ណារឿនៈ ទីបីបានតែពីរកំប៉ុងទេ?

យនៈ ទីបីបានតែពីកំប៉ុងទេ កូនក្មេងនោះ ។ គានេះកិនឲ្យខ្ញុំសិរិតឲ្យខ្ញុំ ខ្ញុំមានធ្វើអីកើត ។

ណារឿនៈ អាហ្នឹងក្នុងមួយនាក់អ្វែសអ៊ុំ?

យនៈ ម្នាក់ ។ ចេញទៅ អាចេញទៅ ណាចេញទៅ យើងជិតៗហ្នឹងយើងបានរបបយើងហ្នឹង ទៅ មិនចេះធ្វើញុំាផងហ្នឹងខ្ញុំ ។

ណារឿនៈ ចែកស្រូវហ្នឹងបានរយៈពេលប៉ុន្មាន?

យនៈ ទេយូរដែរ ។

ណារឿនៈ ប៉ុន្មានខែបានឈប់អ៊ុំគិតមើល ។

យនៈ បួនប្រាំប្រាំមួយខែដែរ គានេះសមរភូមិមុខរហូត ។

ណារឿនៈ ដល់ពេលចែកហើយ...

យនៈ អត់ចាំទេ ។

ណារឿនៈ យូរដែរអត់ បានមួយឆ្នាំទេ?

យនៈ មិនដល់មួយឆ្នាំទេ មិនមែនរឿងឆ្នាំទេ អាហ្នឹងរឿងខែ និយាយរឿងខែដល់អាក្រោយ.....

ណារឿនៈ គេចូលសហករណ៍តែម្តងក្រោយមកអ្ហែស?

យនៈ ចា៎! ឲ្យទៅញ៉ាំនៅការដ្ឋានហើយ ឈប់ចែកហើយ ។ សម័យណាក៏ដូចសម័យណាដែរ និយាយគ្នាទៅវិភាគទៅណា

អត់ចោលទេអាគំនិតដែលអ្នកណាកាន់ស៊ីអ្នកនោះស៊ីហ្នឹង ណា ។ នៅអាពតនៅតែស៊ី ។

ណារឿនៈ នៅអាពតនៅតែស៊ីអ្ហែស?

យនៈ ទាំងកញ្ជើ១ដូរមាសទាំងចង្វាយ១ យើងលួចបានមួយកំប៉ុងអីភ័យខ្លាចតែស្លាប់ហ្នឹង ។

ណារឿនៈ នៅតែពុករលួយដែរ?

យនៈ ដូចតែគ្នាហ្នឹងកុំនិយាយមីកាន់កន្ទែងកិនអង្កវាយកទៅផ្ទះវា សុទ្ធតែសិតស្អាតហ្នឹងថេង យកទៅដូរ ។

ណារឿនៈ អ៊ុំមុនដំបូងគេចែកស្រូវតាមគ្រួសារតាមកំលាំងទីមួយទីពីរអីអញ្ចឹងក្រោយមក..?

យនៈ ចូលសហករណ៍ហើយ ។

ណារឿនៈ គេហៅសហករណ៍ផ្ទះបាយរួមហ្នឹងអ្ហែស?

យនៈ ហ្នឹងហើយ ឆ្នាំងធំ ធុងសាំងនោះ ។

ណារឿនៈ

អញ្ចឹងដូចថាឧទាហរណ៍ថានៅក្នុងគ្រួសារយើងមានមនុស្សចាស់អីគាត់ឈឺអីទៅបាយ រួមអត់កើតអញ្ចឹងអ្ហាស៎ យើងខ្ចប់យកមកឲ្យបានដែរទេ?

យនៈ មុនដំបូងបាន ដល់ក្រោយអត់ទេ ឲ្យមើលចៅទៀតណា មិនមែននេះទេ យាយមួយពីរបីនាក់ណា ។ តែខ្ញុំកូនតូចម្តាយខ្ញុំមើលយកកូនគេចូលមកមួយទៀតមើលទៅបានម្តាយខ្ញុំមើលជាប់កូនណា ។

ណារឿនៈ ដូចថាពេលទៅសហករណ៍បាយរួមហ្នឹងហូបបាយទេ?

យន៖ ហូបបាយដល់បានប៉ុន្មានខែពីរបីខែអីអញ្ចឹងទៅដល់យើងខ្វះខាតហើយយើងធ្វើស្រូវ មិនបានគេចេះតែបន្ទោស ថាយើងធ្វើមិនបានអាមួយហ្នឹងគាប៉ុន្មានគោនគេនោះវាអត់បាននោះ តែយប់ឡើងឃើញតែឡាន ។

ណារឿន៖ ឃើញដែរ? .

យន៖ និយាយមិនឃើញម៉េច បញ្ចេញក្នុងជង្រុកនោះ ។

ណារឿន៖ យកទៅណាវិញ?

យន៖ ថាយកទៅចិន ដឹកយកទៅចិន ច្រើនណាស់ព្រែកនិនស្រូវល្អណាស់ ។

ណារឿន៖ ស្រូវកាលហ្នុងធ្វើបានដែរទេ?

យន៖ បានតើ ។

ណារឿន៖ ចុះអត់មានឆ្ងល់សួរគេថាហេតុអី?

យន៖ ទេ ងាប់! ហ៊ានហើបមាត់ ចេះតែនិយាយគ្នាទៅថាធ្វើឡើងចង់ងាប់ហើយស្រូវច្រូតមកណាណី អត់ឲ្យស៊ី ខ្វះខាតសន្សំសំចៃ ។ យើងយកទៅដូរយកស្បៀងអីចូលមក ដូចថាប្រេងអីណា គេនិយាយណា ហើយបន្តិចៗសីលធម៌ឡើងបាញ់វេទិការកំពុងប្រជុំ ។

ណារឿន៖ ពីណាគេប្រាប់ថាស្រូវធ្វើអត់បាន?

យន៖ មិត្តយើងហ្នឹង ។

ណារឿន៖ ប្រធានកងអ្នែស?

យន៖ មីពួកនិរតីស្រីៗហ្នឹងមីស៊ីថ្មើមហ្នឹង ។

ណារឿន៖ នារីខាងនិរតីហ្នឹងគេមកឆ្នាំណាដែរអ៊ុំបើគិតទៅ?

យន៖ ទេនិរតីមកក្រោយទេ ពួកពាយព្យ ។ ដល់ក្រោយមកកុងគ្នាអានិរតីនេះ ។

ណារឿនៈ ដូចថាបើប្រៀបធៀបកាលខាងពាយព្យ័កាន់និងខាងនិរតីកាន់អ្វាស់មួយណាធូរជាង?

យនៈ មកនិរតីសាហាវណាស់ ពួកអត់ចេះអក្សរសុទ្ធពេញធីងហើយ សុទ្ធតែហួបអីហ្នឹងផាត់ៗឡើងមូលៗ សាហាយគ្នាមិនដឹងណាណីទេ ហើយរកតែទឹកអប់រកតែគ្រឿងក្រអូប យប់ឡើងអ្វាស់ យប់ឡើងលាបក្រែមអីឲ្យអ្វាស់...

ណារឿនៈ ពួកនិរតីមកអញ្ចឹងចុះពេលពួកនិរតីចូលមកអញ្ចឹង នារីខាងពាយព្យ័អីគេដកចេញប្តុយ៉ាង ម៉េច?

យនៈ គេដកសំលាប់តគ្នាណា មិនមែនបានស្រួលទេណា ។

ណារឿនៈ អាហ្នឹងឆ្នាំណាដែរអុំ?

យនៈ យើងចូល៧៧អីហើយ ជម្វាស់ហ្នឹងអា៧៨ជម្វាសហ្នឹងពួកមកក្រោយហ្នឹងមិនដឹងពួកមកពីខាងណាទេ ង៉ែញហាង ៗ ចំណាស់ណាក៏ង៉ែញហាងដាក់ខ្ញុំ ហើយហៅសិតតែមី ។

ណារឿនៈ ចុះក្រែងកាលហ្នុងគេម៉ត់ចត់ខាងសិលធម៍អ្វី?

យនៈ ទេ មិនដឹងអីគេ សិតេតែង៉ែញហាង តែបានញ៉ាំ ទៅសុំបាយក្តាំងអីណា៎ ម៉ែៗចង់ហួបល្ពៅអី ង៉ែញចង់អត់ចេះឈប់ទេង៉ែញឃើញគេធ្វើការចង់ងាប់ហើយ ង៉ែញចង់តែង៉ែញទៅដើរទៅរើសទៅ ង៉ែញចុះឲ្យតែគេឲ្យញ៉ាំ ចុះកូននោះអាណិតកូនខ្ញុំកូនឲ្យប្រូងតូចៗមីមួយទៅអាមេរិកទើបតែ៧ឆ្នាំ

អាប្រុសៗឈឺបីមិនដឹងចេញអុចស្វាយ ប្តុចេញ ស្អីប្ញោកគ្នាហើមប៉ុណ្ណាណីកុំតែបានសំដីហ្នឹងទៅសុំស្កសុំអីមកឲ្យលិតអីបានបាត់ហើមខ្ញុំថាងាប់កូនងាប់អីអស់ហើយចេះអត់អីអត់មានរខិតមួយទេតែចេះតែត្បល់ទៅដើរធ្វើឆ្គតធ្វើអីទៅទៅសុំត្រឡាចអីគេទៅ ឲ្យគាត់មកមើលកូនទៅឲ្យមកឃើញដាក់ ស្តែងទៅបានគេឲ្យយើង ។

ណារឿនៈ ដល់គេមកមើលអញ្ចឹងគេឲ្យយើងដែរទេ?

យនៈ ឲ្យចុះដេកតំរាបគ្នាបីអញ្ចឹង ។

ណារឿនៈ គេអត់មានឲ្យថ្នាំអីទេ?

យនៈ មិនដឹងថ្នាំអីអាចម៍ទន្សាយអីអញ្ចឹង ហើយខ្ញុំចេះមើលអក្សរទៅមិនឲ្យទៅចាក់អីផ្តេសផ្តាសម៉េចទៅយកថ្នាំអាចម៍ទន្សាយអីមកឲ្យតែផុតពីកន្លែងគេមកអត់ហ៊ានឲ្យកូនផឹកទេ បើអត់ស្គាល់អក្សរផងហ្នឹង ។

ណារឿនៈ អញ្ចឹងយកមកអុំអត់ឲ្យកូនផឹកទេ?

យនៈ ទេថ្នាំយើងមានអ្នកជិតខាងទៅសុទ្ធតែថ្នាំពេទ្យទៅ ។

ណារឿនៈ ពេលជម្លាសពីនេះទៅយកទៅ?

យនៈ យកទៅខ្លះ ពួកម៉ាកអញ្ចឹងគេយកទៅ ខ្ញុំកុំតែបានថ្នាំគេចាក់ហ្នឹងខ្ញុំចាក់សំបើមណាស់ណា ។ មានបេកូស៊ី មានកាស៊ីប្រូណាតអី យកទៅសុទ្ធតែសសៃទាំងអស់យកទៅ គេមើលខ្ញុំបានរស់ហ្នឹង ។

ណារឿនៈ មានពេទ្យគ្នាយើងទៅពីនេះដែរ?

យនៈ ចា៎! លួចចាក់ឲ្យទៅ ។

ណារឿនៈ មានសារ៉ាំងអីគេដែរ?

យនៈ មានចា៎! ចុះគេហាងថ្នាំ ខ្ញុំលក់ថ្នាំពេទ្យដែរតើខាងជើងផ្សារដែរ តែអត់បានយកទៅ ចុះគេថាយើងទៅមួយភ្លែតនោះ គេមានគំនិតណាគេដាក់ទៅ ហើយខ្ញុំពឹងគីមសៀ ខ្ញុំជួបគាត់ ហើយគាត់ដុកទ័រនៅបាត់ដំបងនោះ ដុកទ័រហ្នឹងពូកែណាស់ទៅជួបគាត់ គាត់ថាង៉ែញបើសិនជាង៉ែញមួលឈាមអីង៉ែញដូរបាយស៊ីទៅជាហើយ ។ អាណាដែលមានយើងដុះឈាមអីស៊ីបាយជា ថាង៉ែញស៊ីបាយជាហើយ កុំទុកមាសឲ្យសោះដូឲ្យបានតែអង្ករមក មើលកូនឈឺអីក៏ដោយ ។

ណារឿនៈ ខាងណាគេប្រាប់អញ្ចឹង និរតីអ្វែស?

យនៈ ទេ ដុកទ័រយើងគ្នាយើង ពីសង្គមទៅជួបអត់ឲ្យផ្ញើមាត់អញ្ចេះ ខ្ញុំឈឺខ្ញុំចុកពោះផឹកចូលក្នុងពេទ្យ ...គីម សាន នៅតើ ដុកទ័រ ...គីមសាន គ្នាខ្ញុំនៅតើទៅជួប មុិចភ្នែកដាក់

ធ្វើអត់ស្គាល់ទៅដល់មានថ្នាំល្អចាក់តែមួយម្តុលបាត់ ។ តែខ្លាចអាពេទ្យហ្នឹងខ្មោចងាប់ពេញហ្នឹង ។

ណារឿនៈ អញ្ចឹងពេលដុកទ័រ គីមសាន ឃើញអ៊ុំគាត់មិចក្អែកធ្វើអត់ស្គាល់?

យនៈ ចា៎! នៅតែងាប់ ។

ណារឿនៈ គាត់លាក់ប្រវត្តិរូបដែរអត់ទេ?

យនៈ ទេ គេដឹងហើយកុំឲ្យយើងស្គាល់ច្រើនអញ្ចឹង កុំឲ្យហៅលោកអីណា៎ គាត់នៅតែងាប់បង្រៀនគេវះអីរួចគេវ៉ៃចោលនៅគល់ស្ពានៗ គីម សៀ គេយកទៅបាត់ហ្នឹងសុទ្ធតែដុកទ័រគ្នាខ្ញុំទាំងអស់ ។

ណារឿនៈ ហេតុអីបានគេយកគាត់ទៅវ៉ៃ?

យនៈ បង្រៀនគ្នាចេះ ។

ណារឿនៈ បង្រៀនចេះទៅគេយកទៅសម្លាប់បណ្តោយ?

យនៈ ចា៎!

ណារឿនៈ នៅឆ្នាំណាដែរ?

យនៈ គីមសាន ប្រហែលជាដើម៧៧ ។

ណារឿនៈ ពេលពួកនិរតីមកហ្នឹងអ្វើស?

យនៈ ចា៎! ឃើញមុខអញ្ចឹងថាកុំធ្វើស្គាល់អី ឃើញពីណាក៏ដោយ ដល់យើងទៅគេចេះចាក់ថ្នាំល្អឲ្យសុទ្ធតែថ្នាំបារាំងណា....ស៊ីញ៉ូគ្នាចាក់ទៅយប់ហ្នឹងឲ្យដឹកឆ្លងទូកមកវិញហើយកុំឲ្យធ្វើមាត់ថាស្គាល់អ្នកណាៗថ្នាំក៏គេចាក់ទៅ ស្រេចតែគេទៅ គ្រាន់តែប្រាប់ជម្ងឺទេ ។ ហើយគាត់បង្រៀនទាំងវះអាប៉ង់ដេស៊ីដអីគ្រប់មុខបង្រៀនគេអ្ហាស៎ ហើយខ្លាចគេឲ្យមើបៗស្បៀកខោខ្មៅ នៅតែងាប់ សុទ្ធតែអ្នកចេះហើយ ។

ណារឿនៈ គេយកគាត់ទៅសម្លាប់នៅណា?

យនៈ នៅគល់ស្ពានព្រែកលួងហ្នឹង កន្លែងព្រែកលួងហ្នឹងពេទ្យព្រែកលួងហ្នឹងខ្ញុំនៅព្រែកនរិនចូលព្រែកលួងហ្នឹងហើយ ។

ណារឿនៈ ជាប់គ្នា?

យនៈ ចា៎! ខ្ញុំនៅស្ទឹងខាងនោះ ។

ណារឿនៈ ឆ្លងស្ទឹងខាងនោះ?

យនៈ ចា៎!

ណារឿនៈ អុំម៉េចដឹងថាគេយកគាត់ទៅសម្លាប់កាលហ្នុង?

យនៈ អ្នកស្រុកខាងហ្នុងគេប្រាប់ អកព្រៃកលួងនៅសព្វថ្ងៃតើ នៅកាន់បានយូរដែរ ។

ណារឿនៈ

ខ្ញុំចង់បញ្ជាក់ត្រង់ថាពេលអ្នកស្រុកដឹងថាគេយកពេទ្យទៅសម្លាប់ហ្នឹងពេលហ្នឹងខាងនិរតី គេមកហើយនៅ?

យនៈ នៅទេ នៅខាងពាយព្យ័នៅឡើយទេ និរតីអាចុងក្រោយគេចាប់ជម្លាសខ្ញុំចេញនេះវាចូល៧/៨ហើយ ។

ណារឿនៈ ចុះអុំពេលនៅកន្លែងព្រែកនិនហ្នឹងអ្នកាស់គេឲ្យអុំចូលសហករណ៍ដែរទេ?

យនៈ ចូល ។

ណារឿនៈ គេហៅសហករណ៍ព្រែកនិនហ្នឹងអ្វែស?

យនៈ សហករណ៍ព្រែកនិនហ្នឹងតែម្តង ។

ណារឿនៈ ប្រធានសហករណ៍ឈ្មោះអីគេ?

យនៈ ឈ្មោះអាហឿន ។

ណារឿនៈ ប្រុសអ្វែស?

យនៈ ចា៎!

ណារឿនៈ ឈ្មោះ ហឿន ។ ចុះអនុប្រធានរបស់គាត់ពីណាគេលើហឿន ក្រោមហឿនហ្នឹងទៀត?

យនៈ បើលើអាអេន ។

ណារឿនៈ អេនហ្នឹងគណៈឃុំ?

យនៈ ចា៎! គណៈឃុំ ។

ណារឿនៈ មានពីណាលើ អេន ទៀតអត់អុំ?

យនៈ មួយទៀតមិនដឹងឈ្មោះអីទេ បីនាក់ ហើយម៉ីប្រពន្ធ អាហឿន ហ្នឹងមិនដឹងគេធ្វើអីទេ នារីអីទេ សុទ្ធតែពួកគេដាច់ខាតគេហើយណា ។ អត់ទេពួកហ្នឹងវាសណ្ដោសដែរ ដូចថាខ្លាំងពេកវាសំរួលដែរ ឆ្មេចក្អែកដែរ ។

ណារឿនៈ ខ្លាំងតែពួកនិរតីទេ?

យនៈ អានិរតីបើយើងត្រូវជាមួយវា យើងទៅលាបក្រែមអីឲ្យវាយើងញ៉ាំផ្អែតតើ ។

ណារឿនៈ យើងទៅធ្វើមុខធ្វើមាត់ឲ្យវាទៅ?

យនៈ ធ្វើមុខធ្វើមាត់ឲ្យវា

យើងទៅដាំបាយអីឲ្យវាហ្នឹងឆាប់ហើយយើងញ៉ាំច្រើនជាងវាទៀត វាអត់ទេ វាវ៉ៃគ្នាវានោះធំៗ ។ ពេលយើងទៅដាំឲ្យវាស៊ី ភ្លៀវាមកតើ ហើយយើងនៅខាងផ្ទះបាយធ្វើឲ្យវាទៅណាដាំទៅ ។ វាម៉ែរួចហើយនៅម៉ែ ចា៎! រួចហើយ ។

ណារឿនៈ ស្រីៗអ្ហែស?

យនៈ ប្រុសៗ ។ បើស្រីៗគេប្រពន្ធនោះ ហើយវាហ្នឹងបើថាឲ្យយើងធ្វើចុងភៅៗហើយ បើខ្ញុំធ្វើចុងភៅទៅខ្ញុំខស្បាហ៍ណាស់ បេះដូងអីបុកគ្រឿងស្ងរទៅឲ្យគ្នាយើងញ៉ាំសប្បាយចិត្ត បើនាក់ផ្សេងមកចេះតែធ្វើឲ្យស៊ីទៅ ស្ងោត្រកួនជ្រុំត្រកួន ជ្រុំតែប្រហុក ហើយប្ដីខ្ញុំរកបានត្រីនេះ យប់ឡើងស្ងោឲ្យឆ្អិនទៅ ព្រឹកឡើងគេមានទឹកប្រហុកឲ្យយើងយកទៅច្របាច់ជាមួយទឹកប្រហុកទៅ ។ ចា៎! ហាន់ដើមចេក ដើមចេកស្ងោឲ្យផុយ ពូតយ៉ាំងស្រួលយកទៅ ញ៉ាំអាហ្នឹងហើយដែលចុកពោះ បានដប់ថ្ងៃប៊ិសនឹងឆាប់ ។

ណារឿនៈ ដូចថាគេហៅអុំទៅធ្វើចុងភៅអីហ្នឹងខាងនិរតីអ្ហែសមិនមែនខាងពាយព្យ័ទេអ្ហែស?

យនៈ អត់ទេមិនមែនខាងនិរតីទេ ខាងពាយព្យ័ទេកាលហ្នុង ។

ណារឿនៈ ខាងពាយព្យអ្វែសគេហៅអុំទៅ ធ្វើចុងភៅ នៅផ្ទះគេប្រជុំគ្នាគេហ្នឹងអ្នាស់?

យនៈ ចាំ!

ណារឿនៈ ពេលហ្នឹងអ្នកណាគេហៅទៅហ្នឹង?

យនៈ ប្រពន្ធប្រធានមេកងទីមួយ ។

ណារឿនៈ ប្រពន្ធមេកងទីមួយ ។

យនៈ តែគេមិនដឹងធ្វើអីទេណា ។

ណារឿនៈ ឈ្មោះអីដែរ?

យនៈ អត់ស្គាល់ទេ ។

ណារឿនៈ ប្ដីគាត់?

យនៈ អត់ទេ អត់ដែលចង់ស្គាល់គេទេ ឲ្យតែរស់អត់មានខ្វល់ទៅសួរឈ្មោះអីទេ ។

ណារឿនៈ គេប្រាប់ថាឲ្យមកធ្វើចុងភៅឲ្យគេ?

យនៈ ចាំ! ធ្វើតែយប់ហ្នឹងមិនដែលទំនេរទេ ។

ណារឿនៈ ម៉ោងប៉ុន្មាន?

យនៈ ម៉ោង៧ ម៉ែឯងទំនេរទេម៉ែដាំបាយ បេះដាំ បេះដាំបាយបានរស់នឹងដាំបាយហ្នឹង ។ ចុះពេលដាំឆ្នាំងប៉ុណ្ណេះដាក់ពេញទៅ .....ត្រីចៀនទៅ ស្ងោមាន់ទាំងមូលអញ្ចឹងទៅ មាន់យើងយកមាន់ទទេទេណា សល់ពីគេយើងយកមាន់ទទេ និងត្រីចៀនក្រមារវេច មកអត់មានពិបាកដាក់អីទេ ។

ណារឿនៈ ប្រឡាក់អីប្រឡាក់ទៅ ។

យនៈ មកដល់ឃើញកូនក្រឡេកភ្ញាមចូលក្នុងមុងពេញ ។ អត់ឲ្យវាមាត់ទេចូលក្នុងមុងចូលហើយ ។ ឪវាមកពីកាប់អូសជួបកាណូតមិត្តយើងហ្នឹងបានបាយកកមកហើយ មួយចំហៀងឆ្នាំងអញ្ចឹងបានស្កក្រហមមកហើយ សូមអំបិលគ្រាប់គេមកហើយ ។

ណារឿនៈ បានអំបិល ស្កមកពីណា?

យនៈ ស្កកាណូតមិត្តយើងហ្នឹងគេរះតាមស្ទឹងហ្នឹង
ពេលណានេះទៅមិត្តអ្នាមានសល់បាយកក
ទេគេថានៅលើទូកណកឡើងទៅចាក់យកទៅ សុំគេមកបានកូនញាំ ។ ឲ្យតែឃើញឪ
មកសប្បាយចិត្តណាស់កូន នាំគ្នាចូលមុងអស់ហើយអត់មានពិបាកនិយាយច្រើនទេ
គ្មាននិយាយអីមួយម៉ាត់ទេ ដឹងតែពីពួយតែម្តង ។ អំបិលផ្អែមណាស់ម៉ែអើយ!
បានតែអំបិលណាស់ បានតែអំបិលមកស្រណោះណាស់ ។

ណារឿនៈ អុំដូចថាកាលទៅដល់ព្រៃកនិនហ្នឹងមាន១២គ្រួសារចេញពីហ្នឹងនៅជាមួយអុំអ្នាស៎
អញ្ចឹងទៅដល់ហ្នឹង ១២គ្រួសារហ្នឹងដូចនៅរស់ច្រើនដែរអ្ហែស?

យនៈ នៅចា៎! នៅរស់តែក្មេងទេ មនុស្សចាស់ក៏ខ្លះងាប់ទៅ ។

ណារឿនៈ ងាប់នៅសម័យហ្នឹងឬសម័យនេះទេ?

យនៈ សម័យហ្នឹងក៏ងាប់ច្រើនដែរ តែហ្នឹងសុទ្ធតែជម្ងឺទេណា ។

ណារឿនៈ ចុះពេលសម័យខ្មែរក្រហមហ្នឹងអត់អីទេ?

យនៈ ជម្ងាសហ្នឹងអត់ទាន់អីទេ ដល់វាវិតខ្លាំងអាពួកមកពីនិរតីអីទៅ ហើមជើងហើមដៃអ្នាស៎
វាអត់ថ្នាំមានតែអាចម៍ទន្សាយអ្នាស៎ លើបម៉េចថ្នាំយើងយកទៅវាចំរុះហើយ
អាលែងតែចង់បានរបស់ញ៉ុំនោះចេះតែដូរអ្នាស៎
ចឺចេងអីក៏មិនសូវហ៊ានញ៉ុំខ្លួនឯងដែរ សុទ្ធតែខ្ចប់ដូរគេហើយ ដូរយកអង្កអីមកនោះ ។
ហើយខ្សែដៃពេជ្រអីសុទ្ធតែអាក្តាម យើងពីដើម បើនៅសព្វថ្ងៃលុយអស់ទាស់ ។
អស់ហើយអង្ក១៥កំប៉ុងមួយខ្សែក្រវ៉ាត់ មាសបាន២៧ កំប៉ុង ។
ខ្សែក្រវ៉ាត់ប្លាកទីនកាត់កង់ទៅ គេថាយកទាំងអស់ ។

ណារឿនៈ នាឡិកាអី?

យនៈ នាឡិកាខ្ញុំអាព៉ដូហ្នឹងគេឲ្យកន្ទះតៅ ។

ណារឿនៈ ថ្ងៃដផនទាឡិការ ។

យនៈ បានតែ១៥កំប៉ុងទេ ជឿសិនមិត្តយើងគេជឿសិន ។ អត់បានឯណារហូតហ្នឹង គ្មានបានឯណាយកនាឡិកាទៅពាក់បាត់ ។

ណារឿនៈ អ៊ុំដូចថាពេលនៅធ្វើការនៅសហករណ៍អីគេមានប្រជុំអីទេ?

យនៈ អ! ប្រជុំណាស់ ប្រជុំដល់ហើយ ។

ណារឿនៈ គេប្រជុំម៉េចខ្លះ?

យនៈ ប្រជុំឲ្យយើងសកម្មការងារខុសសីលធម៌អីបាញ់កន្ទែងហ្នឹងហើយកំពុងតែប្រជុំហ្នឹង ចាប់បានមកឡើងអង្គប្រជុំអញ្ចឹងទៅថាឥឡូវខ្ញុំវាប្រព្រឹត្តអញ្ចេះមួយអញ្ចុះមួយ បាញ់ ទាំងស្រីទាំងប្រុសអ្នាស់ ។

ណារឿនៈ គេឲ្យសារភាពតែម្តងអ្វើស?

យនៈ ចាំ! ឡើងទៅគេអូសដាក់ប្រវ៉ាក់ឡើងទៅ ។ ពុតែប្រជុំឡើងខ្វាចតែម្តង ។

ណារឿនៈ អ៊ុំស្គាល់ទេពីណាគេដែលគេចាប់ដាក់ច្រវ៉ាក់ឡើងទៅ?

យនៈ ទេអត់ស្គាល់ទេខាងស្តី ។ ខ្ញុំនៅព្រែកនរិនមែនតែទៅប្រជុំនៅស្តីណក ។

ណារឿនៈ ទៅប្រជុំនៅស្តី?

យនៈ ចាំ! ស្តីអីដីរីស្វាប់ណក ស្រេចតែគេដាក់ទិសទៅទេ ទៅឆ្ងាយៗណាស់ដើរទៅណា ។

ណារឿនៈ ពេលទៅប្រជុំអញ្ចឹងប្រធានកងបុគណៈឃុំមកប្រាប់ឲ្យយើងទៅហ្នឹង?

យនៈ គេឲ្យខាងកងមេកងអីមកប្រាប់ថាឲ្យយើងទៅ អ្នកដែលថាមិនបានចេញទៅក្រៅយើង នៅក្នុងអ្នាស់ ។

ណារឿនៈ ដូចតាអីគាត់ទៅរួសផ្ទះអីគាត់ទៅៗ?

យនៈ អ! អានេះរឿងគេទេ យើងអ្នកស្រីៗទៅៗ ទៅខុសអីៗទៅឃើញហើយឃើញនឹង ភ្នែក ។

ណារឿនៈ ទៅដល់ឧទាហរណ៍ថាទៅដល់ស្តីហ្នឹងមានប្រជាជនមកពីភូមិផ្សេងៗមកជួបនៅហ្នឹង ដែរទេ?

យ៉ន៖ ដេរ្យងៗមកជួបចាំ!

ណារឿន៖ ច្រើនឬតិចដែរ?

យ៉ន៖ ច្រើនណាស់ ។ មួយកន្លែងៗច្រើនណាស់តែដល់គេអញ្ជើងទៅ គេមានប្រជុំគេមានកម្មវិធីហើយ ។

ណារឿន៖ កម្មវិធីអីគេអុំ?

យ៉ន៖ កម្មវិធីសម្លាប់ហ្នឹង ។

ណារឿន៖ គេប្រាប់?

យ៉ន៖ គេអត់និយាយរឿងសំលាប់ទេ អានេះគេឲ្យធ្វើគំរូ ។

ណារឿន៖ ឧទាហរណ៍ថាពេលកំពុងប្រជុំអញ្ជើង មានអ្នកខុសអីអញ្ជើងគេអូសឡើងចេញមកតែម្តងអ្ហែស?

យ៉ន៖ ឡើងមកលើវេទិការហ្នឹងតែម្តង ។

ណារឿន៖ គ្នាច្រើនទេម្តងៗ?

យ៉ន៖ ទេមួយដងមួយគូរទេ ។

ណារឿន៖ មួយដងមួយគូរ ប្រុសមួយស្រីមួយ?

យ៉ន៖ ចាំ! ប្រុសមួយស្រីមួយ ។

ណារឿន៖ ហើយគេសម្លាប់នៅមុខហ្នឹងឬគេយកទៅណា?

យ៉ន៖ អត់ទេបាញ់នៅកំពុងនិយាយហ្នឹង ថាខ្លាចអាកន្លែងហ្នឹងឯង ។

ណារឿន៖ ខាងណាអ្នកបាញ់?

យ៉ន៖ ពួកមិត្តយើងហ្នឹងមិនដឹងពួកណាខ្លះសុទ្ធតែទីនុយខ្មៅកាំភ្លើងស្ពាយទៅ បាញ់ពីក្រោមទៅតែម្តង ឈរនិយាយថាខ្ញុំខុសហើយកុំយកគំរាប់តាមខ្ញុំអីអញ្ជើងមិត្តទាំងអស់គ្នាគេឡើងប្រកាស់អីអញ្ជើង ។ កំពុងតែនិយាយហ្នឹងផាប់អត់ដឹងខ្លួនទេ ។

ណារឿន៖ គេបាញ់ពីក្រោមទៅ?

យ៉ន៖ ចាំ! គេបាញ់ពីក្រោមទៅ ។

ណារឿនៈ ពេលដែលបាញ់ហ្នឹងមានគណៈឃុំអីនៅហ្នឹងដែរទេ? គណៈឃុំអីមានទៅដែរអត់?

យនៈ ពេលខ្លះដួនកាលមាន ។

ណារឿនៈ អេន អីនៅហ្នុងដែរអ្វែស?

យនៈ ដួនណាមានតែយោធាទេ ។ តែថាពេលណាសម្លាប់ជុំហើយ ។

ណារឿនៈ មានគណៈឃុំអីអ្វែស?

យនៈ មានៗ ជុំគ្នាពេលមានសម្លាប់ជុំហើយ ។

ណារឿនៈ ចុះខាងស្រុកអីគេមានមកដែរទេ?

យនៈ មកៗ ។

ណារឿនៈ អ៊ុំស្គាល់ទេកាលហ្នុងពីណា?

យនៈ ខ្ញុំអត់ស្គាល់គេថានេះគណៈស្រុកអីអញ្ចឹង ។

ណារឿនៈ តំបន់មកទេអ៊ុំ?

យនៈ ទេតំបន់ដូចអត់ ។

**ចប់សាយអេកាស្សែតទី២**

ណារឿនៈ អញ្ចឹងឲ្យតែប្រជុំមានហើយ?

យនៈ មានកម្មវិធីញឹក ។ បើសំលាប់វិញមុននឹងទៅសំលាប់អ្នកណាយកអ្នកណាហ្នឹង
ថ្ងៃហ្នឹងមើលនៅកន្លែងការដ្ឋានមានគេស៊ីផឹកអ្វាស៎ ។
សប្បាយណាស់គេជិះសេះមកគេស៊ីផឹក
យប់ហ្នឹងសំលាប់ហើយនៅភូមិហ្នឹងមានហើយ ។

ណារឿនៈ ឲ្យតែគេស៊ីផឹកនៅកន្លែងភូមិហ្នឹង?

យនៈ ចា៎! ភូមិហ្នឹងមានហើយ មានគេយកចេញហើយ ។

ណារឿនៈ មេចអញ្ចឹង?

យនៈ ទេទម្លាប់គេអញ្ចឹង មុនគេសំលាប់នៅភូមិហ្នឹងគេស៊ីដលលហើយ ស៊ីផឹកឲ្យឡើងលាន
ភ្នែក ។

ណារឿនៈ អ្នកដែលយកគេសម្លាប់ហ្នឹងអ្នែស?

យនៈ យោធា ។

ណារឿនៈ យោធាហ្នឹងនៅក្នុងឃុំហ្នឹងឬមកពីណាដែរ?

យនៈ ក្នុងឃុំហ្នឹងដូនណា មិនដឹងមកពីណាយើងអត់ស្គាល់ច្រើនណា យើងមិនបានទៅសាកសួរគេទេ គ្រាន់តែថាអូនថ្ងៃនេះស៊ីដឹកហើយយោធា មិនដឹងមកពីខាងណាខ្លះទេមានឈ្មោះមកហើយ

ដូនណាទៅគ្នាឯងអញ្ចឹងទៅលួចប្រាប់គ្នាទៅថាយប់នេះមិនស្រួលទេ

បើថាទំនងគេចៗទៅ អត់គេចមិនដឹងគេចទៅណាយើងមិនស្គាល់ផ្លូវ ។

ណារឿនៈ ឲ្យតែមានដឹកស៊ីនៅក្នុងភូមិអញ្ចឹងយើងដឹង?

យនៈ យើងដឹងព្រោះចាំទម្លាប់ អានេះតាមទម្លាប់អ្នាស់ ។,

ណារឿនៈ យើងដឹងថាយកអ្នកនេះអ្នកនោះអីអញ្ចឹងអ្នែស?

យនៈ ចាំ!

ណារឿនៈ ធ្វើអីខុសដែរបានគេយកទៅ?

យនៈ មិនចាំខុសទេប្រវត្តិរូបយើង ប្រវត្តិរូបខ្លាំងណាស់ណាំ គេដឹងយើងពីនោះមកស្រាប់ហើយ ឬក៏អ្នកស្អប់យើងចេកចូកទៅថាអានេះធ្វើការនេះ អានោះធ្វើការនោះ ។ ខ្ញុំគេសួរខ្ញុំរៀនដល់ថ្នាក់ទីប៉ុន្មាន ខ្ញុំថាខ្ញុំនៅបីខែទៀតប្រលងបិប្លូមជិនាន់នោះ ។

ណារឿនៈ ប្រាប់គេត្រង់?

យនៈ ប្រាប់ត្រង់ អត់អីដែរ គ្រាន់តែថាមានអីយកមកឲ្យយើងមើលទៅ ។បើអក្សរបារាំងអីយើងថាយើងអត់ចេះ មើលតែអក្សរខ្មែរបានហើយ ។

ណារឿនៈ យើងចេះតែយើងប្រាប់គេថាអត់ចេះ?

យនៈ ហ្នឹងហើយ ។

ណារឿនៈ

ចុះអ៊ុំដូចថាអ្នកដែលគេយកទៅសម្លាប់ពេលដែលមានប្រជុំអីអញ្ចឹងភាគច្រើនពួកហ្នឹងជា ប្រជាជនមូលដ្ឋានឬប្រជាជនថ្មី?

យនៈ សុទ្ធតែថ្មី មូលដ្ឋានអត់ទេ គេមិនសម្លាប់អញ្ចឹងទេ ។

ណារឿនៈ ហើយភាគច្រើនគេចោទពីបទអីដែរ ខុសសីលធម៌ឬម៉េច?

យនៈ ទេមិនមែនទេយើងធ្វើការពីដើមមក មេដប់ខ្នង មេហាសិបខ្នង ។

ណារឿនៈ ជាមន្ត្រីរាជការអ៊ុំអ្វែស?

យនៈ ចា៎! អាហ្នឹងជាគ្រូបង្រៀន បាត់ខ្លួន ។ នេះម្ចាស់ផ្ទះនេះបងថ្លៃខ្ញុំនេះធ្វើគ្រូបង្រៀនហើយ ពស់ក្បាលពីរ ។

ណារឿនៈ ពស់ក្បាលពីរយ៉ាងម៉េច?

យនៈ អាពតក៏ត្រូវ យើងក៏ត្រូវ អាហ្នឹងគេសំឡេះចោល៧៦ វ៉ៃចោលហើយ ។ ដើរធ្វើការជាមួយវា៧៥ ពេលវាចូលមកយើងមិនដើរធ្វើការជាមួយវាចុង៧៦បាត់ខ្លួន ។

ណារឿនៈ គេចោទយើងថាពស់ក្បាលពីរ?

យនៈ មកវាឲ្យយើងស្លៀកឈុតខ្មៅស្អាតណាស់ នឹកឃើញថាមិនស៊ាប់ទេណា ។

ណារឿនៈ ចុះពេលឡើងនិយាយអញ្ចឹងម្ចាស់អ្នកហ្នឹង អ្នកដែលត្រូវគេសម្លាប់ហ្នឹងថាខ្ញុំធ្វើនេះធ្វើនោះអញ្ចឹង តែអ៊ុំនិយាយម៉ិញថាមានប្រុសមួយស្រីមួយ ។

យនៈ អាហ្នឹងអ្នកខុសសីលធម៌ទេ ក្នុងសម្លាប់មែនទែនអត់មានទេ ក្នុងសីលធម៌ដែលគេបាញ់ហ្នឹងសីលធម៌ទេណា បើថារឿងរ៉ាវអស់នេះ...

ណារឿនៈ អ្នកសីលធម៌ហ្នឹងប្រជាជនចាស់ ឬថ្មី?

យនៈ ទេមានមូលដ្ឋានខ្លះវាមិនអត់ទេ ។

ណារឿនៈ ប្រជាជនថ្មីទេខុសសីលធម៌ហ្នឹង ។

យនៈ ប្រជាជនថ្មីទេ ។

ណារឿនៈ ចុះប្រជាជនចាស់មានខុសដែរទេ?

យ៉នៈ ខុសដែរ តែគេមិនឃើញមានយកទៅដាក់អញ្ចឹងទេ ។

ណារឿនៈ ម៉េចអញ្ចឹង?

យ៉នៈ ទេអាហ្នឹងមិនដឹងម៉េច អាគេសម្លាប់ក៏ស្ងាត់ដែរ តែទម្លាប់វាហ្នឹងមុនសម្លាប់ថ្ងៃឡើង មើលវាទៅ យើងឃើញហើយក្នុងការដ្ឋានបើកាលណាអត់ស៊ីដឹកអត់អីទេ ។

ណារឿនៈ មានជិះសេះមកដែរទេ?

យ៉នៈ ចាំ! ជិះសេះ ។

ណារឿនៈ ធម្មតាអ្នកណាមានឋានៈអីដែរអ្នកដែលជិះសេះហ្នឹង?

យ៉នៈ ទេអត់ដឹងទេ កាលហ្នុងយើងហៅ តែមិត្តយើងៗទាំងអស់ហ្នឹង មិត្តយើងគឺយោធាហ្នឹង ថ្ងៃបើគេស្ទាមាន់គេកាប់គោអីស៊ី...

ណារឿនៈ មានស្រាអីដឹកទេ?

យ៉នៈ ដឹក និយាយមិនដឹកយ៉ាងម៉េចភ្នែកឡើងក្រហមអែ ។ កម្មវិធីពីល្ងាចហ្នឹងប្រុងខ្លួនទៅ យប់ជ្រៅបន្តិចហៅ ចេញពីផ្ទះហើយ ហៅ តែម្តងគ្នាកំពុងតែដេកដូចខ្ញុំជិវាបថា ដេកអ្នាស់ហៅ កន្ត្រប់ចាប់គ្នាពីលើគ្រែ ។

ណារឿនៈ គេប្រាប់ថាម៉េចពេល?

យ៉នៈ គេហៅ ឈ្មោះអញ្ចឹងណាំ ។

ណារឿនៈ ធ្លាប់ឮគេហៅក្បែរហ្នឹងដែរទេ?

យ៉នៈ នៅក្បែរតែយើងមិនបានឮទេ
ឃើញតែគេរូទៅអញ្ចឹងភ័យខ្លួនហើយនៅក្នុងផ្ទះមួយៗ មានអ្នកណាហ៊ានចេញ ។

ណារឿនៈ ចុះស្អែកឡើង?

យ៉នៈ ស្អែកឡើងបានឮ បាត់ហើយ ។

ណារឿនៈ ធម្មតាគេនៅក្នុងគ្រួសារហ្នឹង មានអ្នកមានប្ដីមានប្រពន្ធកូនអីអញ្ចឹងអ្នាស៎ គេចាប់តែប្ដី ឬគេចាប់ទាំងគ្រួសារ?

យនៈ គេចាប់តែប្ដីទេ អត់មានធ្វើទាំងគ្រួសារទេ ។ ដូចតាចាស់ឈ្មោះ កុងស្រេង១ នៅក្បែរផ្ទះខ្ញុំហ្នឹង ដូចថាយើងជម្លាសមកពួកខ្ញុំហ្នឹងទាំង១២គ្រួសារហ្នឹងទៅនៅស្នាក់ ផ្ទះគាត់អ្នាស៎ ដល់ចិញ្ចឹមមាន់ គាត់អាយុ៧៥ គាត់ឃ្វានមាន់គេទៅចេញហៅទៅប្រជុំ អស់គាត់លួចមាន់គេណា៎ លួចមាន់អាអ្នកនៅជាមួយយើងហ្នឹងណា លួចចុះគាត់ចង់ ពេក៧០ឆ្នាយហើយ ធ្វើប្ដីឯឲ្យចាប់គាត់ ។

ណារឿនៈ គាត់មានបានហូបមាន់ហ្នឹងដែរទេ?

យនៈ អត់ អត់បានទេ ហៅទៅវ៉ៃអត់ពាក់អាវទៀត ។

ណារឿនៈ អ៊ុំឃើញដែរទេ?

យនៈ អត់ទេ ខ្ញុំមិនហ៊ានមើលទេ ខ្ញុំអារឿងអញ្ចឹង១ខ្ញុំខ្លាចណាស់ គេថាគេចាប់កុងស្រេងទៅ ហើយ គាត់ថាមិត្តអើយឈប់សិនឲ្យខ្ញុំពាក់អាវសិន គេថាមិនបាច់ទេទៅប្រជុំមួយភ្លែត ហ្នឹងចាំបាច់ពាក់អាវអី យកទៅក្រោយផ្ទះហ្នឹង ។

ណារឿនៈ គេវ៉ៃឬគេបាញ់កាលហ្នុង?

យនៈ អត់ទេវ៉ៃ វ៉ៃហើយដាក់ទៅក្នុងរណ្ដៅហើយគ្រុបគាត់ហើយ ពូសំលេងស្រែកដេរពីក្នុង ដីហ្នឹងមកទៀតណា ដាក់ទំនាយពីក្នុងដីមកឡើងញរ័អញ្ចឹង ពួកហ្នុងនិយាយអ្នាស៎ ។

ណារឿនៈ តាហ្នុងគាត់ស្រែកដេរអ្វើស?

យនៈ ចា៎!

ណារឿនៈ អញ្ចឹងគាត់អត់ទាន់ស្លាប់ផងហ្នឹង?

យនៈ ចា៎! កប់ទាំងរស់ ។ អត់សមទេណា ។

ណារឿនៈ គាត់ចិញ្ចឹមមាន់ហើយអត់ឲ្យគាត់ហូបទៀត?

យនៈ	អត់ទេ ។ ខ្ញុំក៏រិសដែរហ្នឹង ខ្ញុំចិញ្ចឹមបានច្រើនឡើងដើមឈើ យប់ឡើងគេយកទ្រង់មក ស្មើមាន់ ថាចាប់ចុះ ចាប់ទៅវានៅសល់កូនមាន់មួយប៉ុននេះ ។

ណារឿនៈ	នៅលើដើមឈើ?

យនៈ	នៅក្រោមផ្ទះ វារត់ពីលើដើមឈើមកគេចាប់អស់ហើយ ។ នៅសល់មួយថ្ងៃហ្នឹងថ្ងៃសែនស្អែកឡើងម៉ែខ្ញុំថាកូនសល់មាន់មួយគេអត់ដឹងទេ ខ្ញុំថាគេអត់ដឹងទេ អញ្ចឹងធ្វើសែនបន្តិចទៅកូន ។

ណារឿនៈ	សែនចូលឆ្នាំចិន?

យនៈ	ទេមិនដឹងជាសែនក្បាលទឹក ឬសែនស្អីទេណា ។

ណារឿនៈ	សែនចិនសែនខ្មែរ?

យនៈ	សែនចិន ។ លប ៗ ខ្ញុំកំពុងតែអាករ គ្រាន់តែមាន់ហ្នឹងនស្រែកតែមួយញោកតើដល់ស្រែកញោក អាគ្នាឯងមិនដឹងគេធ្វើអីដែរគេមើលការខុសត្រូវណា៎ មកដល់ ។ ខ្ញុំក្រវាត់មាន់ចូលក្រោមផ្ទះផុតទៅ ហើយតែកាំបិតវានៅឈាមហ្នឹងគេសួរថាអ៊ីធ្វើអីហ្នឹងខ្ញុំថាអត់ទេអត់បានធ្វើអីទេតែកាំបិតនៅកាន់អញ្ចឹងសុទ្ធតែឈាម ។ដល់ហើយខ្ញុំថាបងថាំងអើយបងថាំងខ្ញុំនៅសល់កូនមាន់មួយខ្ញុំធ្វើមាន់ ។ផាប់ហើយអ៊ីអើយតែយ៉ាងនេះទៅវីវរហើយអ៊ីឯងមើលទៅរួចមិនរួចទេ ។ខ្ញុំថាបងថាំងចាំខ្ញុំធ្វើរួចខ្ញុំយកទៅឲ្យបងឯងមួយចំហៀងខ្ញុំអង្វរគេណាធ្វើម៉េចទម៉ែគាត់ថាឲ្យសែន ចាំខ្ញុំនេះទៅខ្ញុំជូនបងឯង ។ គេដើរទៅផ្ទះបាត់ទៅ គេអាណិតយើងដែរណា ។

ណារឿនៈ	គេអត់ធ្វើអីដែរអ្ហែស?

យនៈ	អត់ទេ ។

ណារឿនៈ	គាត់ត្រូវជាយ៉ាងម៉េចដែរ?

យនៈ	មិនមែនទេយើងទៅ នៅក្នុងភូមិគេហ្នឹងណា គេម្ចាស់ភូមិអញ្ចឹងណា៎ ។

ណារឿនៈ	ប្រជាជនចាស់នៅហ្នឹង?

យនៈ	ប្រជាជនចាស់ ។

ណារឿនៈ ដល់ពេលអញ្ចឹងអុំយកទៅឲ្យគេដែរទេ?

យនៈ គ្មានទេបោចសិនដល់ពេលប្រាប់គេរួចយើងបោចយកទៅជូនគេណា យកទៅឲ្យតែរួចខ្លួន ។

ណារឿនៈ ទៅដល់គេថាម៉េច?

យនៈ គេមិនថាម៉េចទេ គេថាក្រោយឈប់ណាអត់បានទេណ៎ា អត់បានទេណានេះខ្ញុំទេណា ។ ព្រោះមាន់ហ្នឹងជាមាន់របស់យើងណ៎ា តែមាន់របស់យើងក៏ដោយយោធាវាអត់ទុកទេ វាដាច់ខាតហើយគឺវ៉ៃនៅកន្លែងហ្នឹងតែម្តងអត់និយាយច្រើនទេ ។

ណារឿនៈ ថាំងហ្នឹងយោធា?

យនៈ មានបងប្អូនយោធា ហើយគេក្នុងហ្នឹងគេអ្នកដើរមើលក្តាប់អញ្ចឹងណា ដើររាស់អញ្ចឹង ។

ណារឿនៈ ប្រធានកងប្រធានក្រុមអីអញ្ចឹងអ្អែស?

យនៈ ចា៎! ហើយយើងជំនិតណាស់ ខាងអាវអីយើងមានអីយើងឲ្យវា ។ វាថាអ៊ុំអើយៗខ្ញុំព្រលឹងចុងសក់អ៊ុំឯងបើគេមកជាមួយខ្ញុំធ្វើម៉េចទៅខ្ញុំធ្វើម៉េចជួយរួច ។ អង្វរគេណាគ្មាន បានសែនទេ មាន់ហ្នឹងធ្វើយកទៅឲ្យគេ ។

ណារឿនៈ ចុះអុំនិយាយមិញថាបញ្ហាសីលធម៌ហ្នឹងមានចំពោះប្រជាជនថ្មី ចុះប្រជាជនចាស់មានខ្លាំងដែរអ្អែស?

យនៈ មានដែរ ។

ណារឿនៈ ពួកនិរតីអ្ហាស់?

យនៈ អែអាហ្នឹងវាស្ងាត់ៗគ្នាវាទេ ។

ណារឿនៈ អត់អីទេ?

យនៈ អត់មានកណ្តាលចំណោមដូចពួកយើងទេ ។

ណារឿនៈ តែពួកនិរតីសម្លាប់ដែរអ្នែស?

យនៈ សម្លាប់ដែរ ។ បើប្រជាជនថ្មីយើងគេឲ្យស្រែកអាក្រោះ គេឲ្យស្រែកប្រកាស់មេក្រួតែម្តង ឲ្យថាកុំយកតំរាប់តាមខ្ញុំ ខ្ញុំបានជាខុសទៅហើយ សូមឲ្យមិត្តកុំយកតំរាប់តាមខ្ញុំអញ្ចឹង ស្រាប់តែកំពុងតែនិយាយៗគ្រាប់ទៅដល់ដួងដួលខ្ទប ។

ណារឿនៈ អុំក្រោយមកទៀតនៅឆ្នាំណាគេជម្លាសអុំទៅ ?

យនៈ ៧៨ ជិតដល់ពេលហើយយើងទៅ នៅ នោះបានប៉ុន្មានខែហ្នឹង ។

ណារឿនៈ ជម្លាសទៅណាវិញ?

យនៈ ទៅគោកឃ្មុំ ។

ណារឿនៈ ជាភូមិឬជាឃុំ ?

យនៈ ភូមិគោកឃ្មុំ ចុះពីថ្នល់គោលទៅ នោះ ចូលមុនដំបូងចូលទៅដល់កៀនកេះ ។

ណារឿនៈ គោកឃ្មុំហ្នឹងនៅជាប់ថ្នល់គោលហ្នឹងទេ?

យនៈ ទេចុះទៅជ្រៅ នៅថ្នល់ មាត់ថ្នល់ហ្នឹងទៅញាំបបរគោក គេជម្លាសឲ្យញាំបបរគោក យើងឯណេះទឹកលាងអាចម៍ឲ្យកូនបាននោះ ខ្ញុំនិយាយពីហត់តែទឹកចង់ស្លាប់ហើយ កូនវាអត់ព្រមញាំទឹកនោះ ប្តីក៏ដោយហុតតែទឹកទៅ យកកាកហ្នឹងឲ្យកូន ។

ណារឿនៈ អុំថាមានកូនបួននាក់សម័យហ្នឹងអ្នាស់?

យនៈ ចាំ! បួន ។

ណារឿនៈ អាយុប៉ុន្មានដែរ?

យនៈ កូនធំអាយុ៧ឆ្នាំ ។

ណារឿនៈ គេឲ្យចូលកងកុមារដែរអត់កាលហ្នឹង?

យនៈ ចូល ចូលទៅក្នុងមួយអាទិត្យហ្នឹងសុំគេមកម្តង មកទៅកូនអាំងប្រហុកឲ្យបន្តិចសុំការដ្ឋានគេណាំ ហើយសុំបាយគេបានមួយកូនកញ្ចប់ទៅវិញទៅ ឃ្លានណាស់នៅធ្វើជាមួយគេនៅកងគេចល័តហ្នឹងជួនណាអស់ខោស្លៀកមុងក៏មានដែរ ។ មកអស់ខោ

ហើយសុំគេមកថាអត់មានខោស្លៀកទេណា

ស្លៀកមុងមកអញ្ចឹងទៅ បានខោទៅវិញ ។

ណារឿនៈ ចុះបីនាក់ទៀត?

យនៈ អាបីនាក់ទៀតគេយកទៅដាក់មន្ទីរកុមារដែរតែជិត ។ អាហ្នឹងម៉ោង១២យប់អីរត់មក ហើយ គេមកចាប់ដូចជ្រូកអញ្ចឹង គេរើបណ្តើរយកទៅ ហើយ ។

ណារឿនៈ មានក្មេងរត់មកច្រើនដែរទេ?

យនៈ ច្រើនរត់ប្រសេកប្រសាចច្រើន មកទៅរកឡេងឡឹមរកចង្រ្កានមានអី ខ្ញុំបានចេកបានអី ចែកគ្នាមកពីថ្ងៃ យើងទុកទៅសំរាប់វាមកបានមួយម៉ាត់ក៏ទៅវិញដែរ ។ គេចាប់ច្របល់ លោកអើយៗ វេទនាណាស់ ។

ណារឿនៈ ពីរនាក់ទៀតនៅជាមួយអ៊ុំទេ?

យនៈ ជាមួយម្តាយខ្ញុំ ៗមើល អាមួយពៅ គេនេះដូចជាមិនសូវចាំផង ។

ណារឿនៈ ប្រុសប៉ុន្មានស្រីប៉ុន្មានដែរអ៊ុំ?

យនៈ ប្រុសបីស្រីមួយ ។ មីនេះមីពៅ នេះទើបតែមានក្រោយ៨៤នេះទេ ។

ណារឿនៈ អញ្ចឹងប្រុសបីស្រីពីរ ។ អ៊ុំពេលដែលគេជម្លាសទៅ គោកឃ្មុំហ្នឹងគេប្រាប់ថាម៉េច?

យនៈ គេថាយើងនេះវាខូត់ វាអត់មានអីឲ្យហូប ឲ្យជម្លាសចេញ ៗគេដាក់អ្នកថ្មីមកទៀត ។

ណារឿនៈ ពេលដែលគេជម្លាសហ្នឹងពួកនិរតីគេប្រាប់អ្វីស?

យនៈ គេប្រាប់ហើយគេដើរចាប់ដាក់ឡានទៅអូ្ហស៍ ភ្លៀងវេទនាដល់ហើយទៅដល់គោកឃ្មុំ ហ្នឹងចំអាឈ្មើងស្រែឈ្មើងមែនទែននិយាយពីបងប្អូនងាប់ហើយ តែប្តីខ្ញុំអត់ចេះខ្វាចអី ទេ ។

ណារឿនៈ ជម្លាសទៅទាំងអស់គ្នាឬក៏...?

យនៈ មិនមែនទេ ទៅមួយវគ្គអញ្ចឹងទៅ ទៅត្រាង ទៅស្មឿ បីវគ្គ ។

ណារឿនៈ មុនដំបូងមុនគេជម្លាសទៅ គេមានហៅ ប្រជាជនប្រជុំដែរទេ?

យនៈ ប្រាប់គេប្រជុំថាបែកខាងនោះឲ្យទៅខាងនោះមួយវគ្គអញ្ជើងទៅ
ទីពីរអញ្ជើងគេប្រកាស មួយបែកអញ្ជើងទៅខ្ញុំចុងក្រោយគេ ។

ណារឿនៈ អញ្ជើងអ៊ុំដូចជាអ្នកដែលមកហៅ កោះប្រជុំហ្នឹងខាងឃុំឬខាងគណៈកង?

យនៈ ខាងឃុំ ។

ណារឿនៈ ឈ្មោះដែរពេលហ្នឹង?

យនៈ អាឃុំឈ្មោះអាអេនដដែលហ្នឹង ។

ណារឿនៈ អញ្ជើងពេលនិរតីមកកាន់ហើយហ្នឹង អេនអីនៅដដែលអ្ហែស?

យនៈ នៅ អាអេន អាហឿន អីនៅតើ ។ គណៈភូមិ អាហឿន ។

ណារឿនៈ គេប្រាប់ថាគេចែកជាបីដំណាក់កាល ពេលជម្លាសទៅ ហ្នឹងអ្ហែស?

យនៈ ចា៎!

ណារឿនៈ អ្នកប្រជាជនប្រភេទណាដែលគេជម្លាសទៅដំណាក់កាលទីមួយ ដំណាក់កាលទីបី?

យនៈ សុទ្ធតែថ្មី គ្នាយើងទាំងអស់ហ្នឹង ។

ណារឿនៈ មូលដ្ឋានអត់ទេ?

យនៈ ទេអត់ទេ យើងមួយកាត់ៗអញ្ជើងគ្រាន់តែថាមុនហើយនឹងក្រោយ ។

ណារឿនៈ ដំណាក់កាលទីមួយហ្នឹងគេជម្លាសទៅណាដែរ?

យនៈ ទីមួយទៅត្រាង ។

ណារឿនៈ ទៅភូមិត្រាងក្នុងខេត្តណាដែរ?

យនៈ ទីពីរសៀ ។ សិរីសោភាន់ហ្នឹង ។

ណារឿនៈ ទៅត្រាងប៉ុន្មានគ្រួសារដែរ?

យនៈ ទេកាលហ្នុងដូចជា២០គ្រួសារ ។ មួយវគ្គបែកគ្នាហើយណា១២គ្រួសារហ្នឹងទៅបីវគ្គ
បែកគ្នាទាំងបីវគ្គហើយអត់មានជុំគ្នាទេ គេត្រូវឈ្មោះទៅមុនទៅៗ ។

ណារឿនៈ ចុះវគ្គទីពីរ?

យនៈ វគ្គទីពីរចូលសឿ ។

ណារឿនៈ នៅសិរីសោភណ្ឌដែរ?

យនៈ ចាំ!តែទៅម្តុំហ្នឹងសំបូរញ៉ាំតើ ។

ខ្ញុំក៏តែបានទៅគោកឃ្មុំហ្នឹងម្តាយខ្ញុំអីបែបស្លាប់អស់ ហើយចុះបើរាវណាស់នោះ ។

ណារឿនៈ ចុះអ៊ុំថាគេហៅទៅដាំបាយអីបានខ្លះនោះ?

យនៈ ទេអាហ្នឹងមុនទេ ដល់ចុងក្រោយអស់ហើយយើងមិនបានធ្វើដាំបានទេ ពួកមីអស់ហ្នឹងគេបញ្ចេញហើយ គេបញ្ចេញមិននិរតីមក ។

ណារឿនៈ និរតីមកគេតឹងគេអត់ឲ្យដាំបាយទៀតទេអ្ហែស?

យនៈ អត់ទេ មីអស់ហ្នឹងវាសិតតែ ដូចវាក្រមុំៗនោះ គ្រកៀកវាប៉ុនៗនេះលោកអើយធាត់នោះធាត់ដល់ហើយពួកមីប៉ុន្មាននាក់ហ្នឹងដល់ហើយសុទ្ធតែគោឡើងក ។ ហើយវាយកម៉ែៗមានមាសទេធ្វើខ្សែដែកកេះ ធ្វើបញ្ចេះចង្កៀង ពេជ្រវាដាក់នៅក្រោមដាក់ជាមួយប្រេងកាតដុត ពូថៅវាឲ្យគេធ្វើពូថៅមាស ។

ណារឿនៈ ខាងនិរតីហ្នឹង?

យនៈ ចាំ!

ណារឿនៈ អ៊ុំពេលគេជម្លាសអ៊ុំទៅដល់គោកឃ្មុំទៅដល់ហ្នុងភ្លាមគេឲ្យអ៊ុំធ្វើអីដែរ?

យនៈ ប្រូតស្រូវៗបានគុណដំបៅខ្ញុំដំបៅជើងជ្រៅ ចុះទៅឈឺណាស់ទំរាំចុះទៅលែងកើតវាហើម បាននៅគោក ដល់ហើយនិយាយពីឈ្លើង ចុះទឹកត្រឹមនេះ ឈ្លើងរត់ស្រែកឲ្យម៉ែជួយពេញស្រែហ្នឹង ។

ណារឿនៈដូចថាពេលគេជម្លាសអ៊ុំទៅគោកឃ្មុំអញ្ចឹងកូនអ៊ុំនៅកងកុមារនេះគេឲ្យទៅជាមួយដែរ?

យនៈ ទៅចាំ! ទៅជាមួយឲ្យប្រមូលកូនចៅទៅជាមួយ ទៅជុំគ្នាចាំទៅជុំគ្នា ។

ណារឿន៖ ទាំងតាទាំងអី?

យន៖ ចាំទៅ ។

ណារឿន៖ ទៅដល់ហ្នុងនៅខាងគោកឃ្មុំហ្នឹងខាងនិរតីគេកាន់ដដែល អ្ហែស?

យន៖ កាន់ គ្រាន់តែថាគេអ្នកមុនគេផ្សេងគេនៅឃុំគោកឃ្មុំគេហ្នឹងយើងនេះអត់ទេ ។

ណារឿន៖ ឃុំគេឈ្មោះអីដែរ?

យន៖ អត់ទេ

ហ្នឹងងងឹតឈឹងហើយលែងដឹងទិសដំបន់ហើយគោកឃ្មុំលែងស្គាល់អ្នកណាអ្នកណី ទាំងអស់ ។

ណារឿន៖

ចុះអ៊ុំដូចថាបងប្អូនអ៊ុំផ្សេងទៀតជីដូនមួយសាច់ញាតិអីហ្នឹងពេលជម្លាសទៅហ្នឹង មានទៅ ហ្នឹងដែរអត់?

យន៖ ទៅជីដូនមួយ ។

ណារឿន៖ ក៏ទៅតែគ្រួសារអ៊ុំទេ?

យន៖ ទេទៅ ទៅម្ដាយមីងគាត់ហ្នឹងជីដូនមួយណាំគាត់ហ្នឹងជាប់កូនទៅពីរកូននៅ ពេញជាមួយឪពុកទៅជីដូនមួយទៅពីរនាក់ដែរ ហើយសុទ្ធពីហ្នឹងសុទ្ធតែញាតិនៅក្នុងភូមិទេ ។

ណារឿន៖ អ៊ុំដូចថាឆ្នាំ៧៥អ៊ុំគេជម្លាស់អ៊ុំមកនៅកន្លែងព្រែកនរិន ចិនដាំស្ដែអីហ្នឹងនៅហ្នឹងរហូត មានប្រជាជនថ្មីគេជម្លាសពួក១៧មេសាគេជម្លាសមកពីភ្នំពេញដែរទេ?

យន៖ អត់ឃើញ ។

ណារឿន៖ អញ្ចឹងប្រជាជនថ្មីដែលនៅហ្នឹងសុទ្ធតែអ្នកផ្សារបាត់ដំបងទេ?

យន៖ ផ្សារបាត់ដំបង ។ អ្នកភ្នំពេញខ្លះទៅស្ដី ដំរីស្លាប់ណកមានអ្នកភ្នំពេញខ្លះ ។

ណារឿនៈ នៅឆ្នាំ៧៧, ៧៨ហ្នឹងមានប្រជាជនខាងព្រៃវែង ស្វាយរៀងគេជម្លាសមកខាងហ្នឹងដែរទេ ខាងអកល្បឿងខាងអីអ្នកស្រី?

យនៈ អត់មានទេ ឃើញតែគ្នាឯង។ ឃើញតែគ្នាយើងហើយនិងផ្លាស់ពួកអាមេៗវាហ្នឹងអាស្រីដែលមកពីខាងនិរតីហ្នឹង។

ណារឿនៈ ពេលអ៊ុំទៅដល់គោកឃ្មុំមានប្រជាជនថ្មីនៅហ្នុងដែរទេ?

យនៈ មានតែពួកយើងហ្នឹងហើយ។

ណារឿនៈ មានពួកភ្នំពេញដែរទេនៅហ្នុង?

យនៈ អត់ឃើញ។

ណារឿនៈ បើអញ្ចឹងខ្ញុំសួរថែមបន្តិចទៀតទាក់ទងរឿងគ្រួសារតា នួន ជា អ្នកស្រី។ អ៊ុំថាកាលមុនតាវ៉ិ ត្រូវជាប្អូនប្រុសរបស់តា នួន ជា សព្វថ្ងៃគាត់ស្លាប់ហើយ។ អញ្ចឹងតានួន ជា គាត់មានបងប្អូនប៉ុន្មាននាក់ដែរអ៊ុំ?

យនៈ បងប្អូនច្រើន។

ណារឿនៈ យាយពាញហ្នឹងគាត់មានកូនប៉ុន្មាននាក់ដែរ?

យនៈ ម្តាយ។

ណារឿនៈ គាត់មានកូនប៉ុន្មាននាក់?

យនៈ ចាំខ្ញុំរាប់សិន នួន ជា អ៊ីគ្រឿត អ៊ី ហ៊ិច មារ៉ី នាងនី នៅកូនប្រាំ។

ណារឿនៈ ចុះទាំងអស់សរុបទាំងអស់ប៉ុន្មាននាក់?

យនៈ ប្រាំ។

ណារឿនៈ ទាំងស្លាប់ទាំងរស់?

យនៈ អត់ទេទាំងស្លាប់ទាំងរស់។

ណារឿនៈ អ៊ីគ្រឿតនេះស្រី ប្រុសតែតានួន ជា មួយទេ?

យនៈ នួន ជា និង មារ៉ី។

ណារឿនៈ នី ស្រីដែរ?

យន: ចាំ! នៅអាមេរិក ។

ណារឿន: ប្ដីគាត់ឈ្មោះអីដែរ?

យន: អត់ដឹងគេបានប្ដីនៅអាមេរិកណាក ។

ណារឿន: វី ស្លាប់បាត់ហើយ ហ៊ុច ស្លាប់ដែរ ។

យន: ទើបតែស្លាប់យើង២០០១នេះទេ ។ នៅរស់តែមួយនាក់ពីរនាក់ ។

ណារឿន: អញ្ចឹងនៅរស់តែបីនាក់ទេ...

យន: នួន ជា និងអ៊ុនី ។

ណារឿន: នៅអាមេរិកមួយនៅវត្តគរមួយ នួន ជា គាត់នៅប៉ៃលិនណាក ។

យន: នួន ជា ឈ្មោះ គន អ្ហាស់ ។

ណារឿន: ឈ្មោះអីគេ.?

យន: ឈ្មោះ គន ។ នួន ជា នេះងាវខ្មែរក្រហមទេណា ។

ណារឿន: ចុះកាលមុនគាត់ឈ្មោះអីគេដែរ?

យន: ឈ្មោះ គន- ឡាវស៊ីគនទេ តែគេប្រែយ៉ាងម៉េចយើងអត់ដឹងទេណា ។

ណារឿន: គាត់ប្រើត្រកូលអីដែរ?

យន: ត្រកូលឡាវ ។ ព្រោះឪគាត់ឡាវអ្ហាស់?

ណារឿន: ឪគាំឈ្មោះតាឡាវ?

យន: ទេមិនមែនទេ ខ្សែទេ ចិន ខ្សែឡាវ ។ ឈ្មោះ កុងអីទេ ។

ណារឿន: ចុះកាលដែលយាយពាញគាត់នៅផ្សារបាត់ដំបងនេះប្ដីគាត់ដែលទៅស្រុកចិនហ្នឹងដែល មកលេងដែរអត់?

យន: ទេខ្ញុំកើត ខ្ញុំជួបអត់ដែលឃើញ ខ្ញុំនៅក្មេងៗអត់ដែលដឹងអី ។

ណារឿន: គាត់មានកូននៅសល់ទេសព្វថ្ងៃ តានួន ជា អ្ហាស់,?

យន: នួន ជា កូនគាត់នៅតើ មានកូនតើ ។

ណារឿនៈ អ៊ុំស្គាល់ដែរទេ.?

យនៈ ទេអត់ដែលសោះ អត់ដែលទេខ្ញុំអត់ដែលសោះ ។

ណារឿនៈ កាលគាត់នៅក្មេង គាន្ធួន ជា គាត់រៀននៅសាលាបាត់ដំបងហ្នឹងដែរអត់ទេ?

យនៈ ពួកនេះមុនដំបូងរៀននៅបាត់ដំបងហើយ ។

ណារឿនៈ រៀនស្រុករបងរបស់អ៊ុំដែរអត់ទេ?

យនៈ ទេអត់ទេមុន ន្ទួន ជា រៀនមុន ។

ណារឿនៈ អ៊ុំមានដឹងថាគាត់ទៅថៃទៅអីដែរអត់កាលហ្នុង?

យនៈ ទេមិនសូវដឹង ដឹងតែថាធ្វើកម្មករកប៉ាល់អីដឹង តែត្រង់អីផ្សេងអត់ដឹងទេ គាត់នៅតែធ្វើកម្មករនេះទេ មិនដែលធ្វើស្អីទេមិនដែលចេញមុខទេ ។ គាត់បង្កប់យ៉ាងម៉េចយើងអត់ដឹងទេណា នៅតែដែរកប៉ាល់ហ្នឹង ។

ណារឿនៈ ចុះនៅវត្តគរហ្នឹងបងប្អូនជីដូនមួយគាត់អីមាននៅទេ នៅភូមិវត្តគរហ្នឹង?

យនៈ មានជីដូនមួយខាងម្ដាយ ប្អូនម្ដាយអីនៅពេញហ្នឹងទាំងអស់តើ នៅច្រើនណាស់ ។ ចុះប្រពន្ធស៊ីវ ហេង ជាន់នេះអីនៅហ្នុងដែរតើ ។ ទេមិនដឹងនៅមិននៅទេ ។

ណារឿនៈ ប្រពន្ធតាស៊ីវ ហេង ឈ្មោះអីដែរ?

យនៈ "ដូចជានៅផ្ទះចាស់ហ្នឹងតែតាហ្នឹងគាតង់ខូចហើយដែលយើងអត់បានទៅណា" ទេមិនមែនទេ ហ្នឹងប្អូនមាពាញបង្កើតទេ ។

ណារឿនៈ ប្រពន្ធតាស៊ីវ ហេង?

យនៈ ទេខ្ញុំដូចជាភ្លេចទៅ ។

ណារឿនៈ ស្រុកកំណើតគាត់នៅណាដែរ?

យនៈ នៅវត្តគរទាំងអស់ហ្នឹង ។

ណារឿនៈ បើសួរគេនៅវត្តគរគេស្គាល់ដែរទេ?

យនៈ សួរថីមិនស្គាល់ ។

ណារឿនៈ ចុះអ៊ុំដូចថាតាំងពីឆ្នាំ៧៩ បែកវៀតណាមចូលមកអញ្ចឹងអ្នកស៊ើ គ្រួសារអ៊ុំត្រឡប់មកស្រុកមកភូមិវិញឬទៅណាទៀត?

យនៈ នៅថ្មគោលសិន ទាល់តែអាពតវ៉ៃបែកថ្មគោលបានរត់មកដល់នេះ ។

ណារឿនៈ វៀតណាមវ៉ៃបែកថ្មគោលក៏អាពតវ៉ៃបែក?

យនៈ អាពតវ៉ៃមុនដឹបូងអ្នកស៊ើ បានអណ្តែតមកដល់នេះ ដល់វៀតណាមដេញអាពតទៅវិញបានៗស្រួល ។

ណារឿនៈ អ៊ុំដូចថាឆ្លងកាត់របបខ្មែរក្រហមអញ្ចឹង អ៊ុំមានបាត់បងប្អូនសាច់ញាតិអីដែរអត់?

យនៈ បាត់តែឪពុកមាថ្លៃ ហើយកូនចៅមិននេះទេ មកបាត់ប៉ុន្មាននាក់ ។ ខ្ញុំមួយគ្រួខ្ញុំបាត់តែសេងលីមួយទេ ។ ផុតពីហ្នឹងបងប្អូនអីជុំ មកខូចយើងឥឡូវនេះទេណា ។

ណារឿនៈ

សព្វថ្ងៃអ៊ុំដែលនិយាយរឿងរ៉ាវដែលកើតឡើងនៅសម័យខ្មែរក្រហមហ្នឹងប្រាប់ក្មេងៗ ដូចកូនអ៊ុំអីដែរទេ?

យនៈ ប្រាប់ដែរតែគេអត់ជឿ ។

អត់ជឿទេក្មេងឥឡូវវាថាស៊ាប់ហើយបើអញ្ចឹងរស់យ៉ាងម៉េច កើត វាអត់ជឿមែន ។

ណារឿនៈ អ៊ុំដឹងថាហេតុអីបានវាអត់ជឿអញ្ចឹងដែរទេ?

យនៈ មិនដឹង ។

ណារឿនៈ

អ៊ុំសព្វថ្ងៃអ៊ុំដែលឮរឿងរ៉ាវទាក់ទងនឹងការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែរទេ?

យនៈ សព្វថ្ងៃអាមេរិកកាំងនិយាយរាល់តែថ្ងៃហ្នឹងស្ដាប់រាល់តែថ្ងៃហ្នឹង ។

ណារឿនៈ អ៊ុំឮដែរអ្ហែស?

យនៈ ចា៎! តែមិនដឹងជាកាត់ទោសយ៉ាងម៉េច វាដូចជាពិបាកដែរព្រោះថា អានេះនិយាយទៅអានេះប្រទេសជាតិវាទាក់ទងច្រើនណាស់ ។

ណារឿនៈ ព្រោះតុលាការហ្នឹងធ្វើឡើងគេកាត់ទោសតែមេដឹកនាំធំៗទេ គេកាត់តែប៉ុន្មាននាក់ទេ ។

យនៈ អញ្ចឹង ។

ណារឿនៈ ថ្នាក់ទាបៗ គេអត់កាត់ទេបើកាត់ទៅ វាជាប់ច្រើនណាស់ ។ អញ្ចឹងចំពោះអ៊ុំចង់ឲ្យគេបង្កើតតុលាការហ្នឹងដែរអត់?

យនៈ អាខាងហ្នឹងខ្ញុំដូចមិនយល់ ខ្លួនឯងដូចមិនអាចនិយាយថាម៉េចកើតណា ។

ណារឿនៈ ព្រោះសាលាក្ដីហ្នឹងគេធ្វើឡើងសំរាប់ប្រជាជន ដើម្បីរកយុត្តិធម៌ឲ្យប្រជាជនដែលបានបាត់ខ្លួនឬក៏ស្លាបបាត់បង់ជីវិតកាលពីសម័យហ្នុងអ្ហាស់ អញ្ចឹងគេចង់ដឹងពីប្រជាជនម្នាក់ៗទៅវិញជាគំនិតផ្ទាល់ខ្លួនថាចង់ឲ្យមានតុលាការហ្នឹង សំរាប់កាត់ទោសមេដឹកនាំជាន់ខ្ពស់ហ្នឹងដែរអត់ ។ ចំពោះគំនិតអ៊ុំវិញអ៊ុំគាំទ្រឲ្យមានតុលាការហ្នឹងដែរអត់?

យនៈ មានតុលាការហ្នឹងក៏ល្អម្យ៉ាងដែរព្រោះថាអានេះគេរកយុត្តិធម៌ឲ្យណា ។

ណារឿនៈ ហេតុអីដែរអ៊ុំ?

យនៈ អានេះដូចជាចង់ដឹងខុសត្រូវដែរណា៎ អានេះដូចថាយើងអត់យល់ ដែលយើងទៅក្នុងរបបខ្មែរក្រហមក៏យើងងងឹតឈឹង អត់ដឹងថារឿងអី ដូចថាគេបង្កើតអញ្ចឹងក៏ល្អដែរព្រោះថាយើងវាមានបាត់បងបាត់អីអញ្ចឹងដែរណា ។

ណារឿនៈ អ៊ុំដូចថាបើសិនជាមានតុលាការហ្នឹងអ៊ុំចង់គេដាក់ទោសពួកហ្នឹងកំរិតណាដែរ?

យនៈ មិនដឹង ។

ណារឿនៈ ស្រាច់តែច្បាប់គេអ្ហែស?

យនៈ ចា៎! ស្រេចតែច្បាប់ព្រោះយើងមិនចេះអី ...គេមានវិធីគេហើយមិនបាច់យើងចេះអីទេមែនទេ ។

ណារឿនៈ ខ្ញុំដូចជាអស់អីត្រូវសួរអ៊ុំហើយ អ៊ុំមានអីចង់បន្ថែមអ៊ុំអាចប្រាប់ខ្ញុំបាន ។

យន: អត់ទេស្ទត់នឹងបងនេះមិននឹកស្មានថាថ្ងៃនេះបានដឹងដំណឹងអ្ហាស៎ ដឹងទៅដូចថាឲ្យអារម្មណ៍យើងស្ងប់អ្ហាស៎ដូចថាហោរថាហោរហ្នឹងចេះតែភូតហើយ ។

ណារឿន: ដល់ពេលដឹងអញ្ចឹង?

យន: ស្រណោះព្រោះអត់ដែលបានជួបគ្នាតាំងពីយើង ៦០ គត់មកដល់ឥឡូវ ។

ណារឿន: ៤៦ឆ្នាំហើយ ។

យន: អត់ដែលជួបគ្នាអត់ដែលឮអី ហើយសួរគេថាស្លាបហើយក៏យើងអត់មានប្រាកដ ដល់អញ្ចឹងបាននឹកឃើញ មិនដឹងគេធ្វើបាបយ៉ាងម៉េចណា៎ តែដូចថាគេធ្វើបាបហើយយើងមិនអាចបញ្ចេញកំហឹងតែចំពោះយើងមួយគ្រួសារហ្នឹងទៅរួចទេ

អានេះសំរេចទៅ លើច្បាប់ដែលគេដឹងច្បាប់គេចេះហើយមិនមែនយើងចេះដាងច្បាប់ទេណា ។

ណារឿន: អញ្ចឹងខ្ញុំអរគុណអ៊ុំច្រើន ។

យន: ចា៎! អរគុណហើយខ្ញុំដឹងដំណឹងនេះខ្ញុំដូចឲ្យអស់ចិត្តណា៎...ដូចថាអន្ទុយចាំ ជួនណាទៅនឹកឃើញថាបងមកដល់ចៃដន្យក៏មាន តែឥឡូវអស់ចិត្ត ។

ណារឿន: អញ្ចឹងអរគុណអ៊ុំ!

**-ចប់-**